# វិន័យសាមណេរ

ប្រមូលរៀបរៀង

ដោយ

ទៀង - យន់ និង អួច - ងឿន

ផ្សាយគ្រៀតិ

លេខ ១៩៥ វិថីឧកញ៉ាអ្នូរ ភ្នំពេញ

បោះពុម្ពលើកទី ៤

ព.ស. ២៥១៦  គ.ស. ១៩៧២

រក្សាសិទ្ធិ

Websites: WatKhemaraRatanaram.org or WatKhmers.org

# រាហុលបព្វជ្ជា

កុមារបួសជាសាមណេរមុនគេ !

គម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទ សំដែងថាៈ

កាលព្រះសម្មាសម្ពុទ្ធគង់ក្នុងនិគ្រោធារាម ជិតក្រុងកបិលវត្ថុ ក្នុងដែនសក្កៈ សម័យមួយព្រះអង្គទ្រង់ស្បង់គ្រងចីវរ ស្ពាយបាត្រ ស្តេចចូលទៅដំណាក់ព្រះបាទសុទ្ធោទនៈ ក្នុងវេលាព្រឹក ទ្រង់ប្រោសព្រះពុទ្ធបិតា ព្រះនាងមហាបជាបតិគោតមី និងព្រះនាងពិម្ពា ឱ្យតាំងនៅស៊ប់ក្នុងអរិយមគ្គ រួចហើយ ថ្ងៃទី ៣ ទ្រង់យាងទៅនាំ នន្ទ ដែលកំពុងតែរៀបអាពាហ៍ពិពាហ៍ជាមួយនាង ជនបទកល្យាណី មកឱ្យឧបសម្បទា ។ បន្ទាប់ពីបំបួសនន្ទ បាន ៧ ថ្ងៃ ទ្រង់បំបួសរាហុលជាបុត្រទៀត ។

សេចក្តីថា កាលនោះព្រះនាង យសោធរាពិម្ពា បានរៀបចំតុបតែងកាយឱ្យរាហុលកុមារជាបុត្រសំឡាញ់ ហើយបង្ហាញប្រាប់ថា "ម្នាលកូនប្រុសមាតា ចូរបាមើល ! សមណៈ កំពុងបិណ្ឌបាតនុ៎ះ ត្រូវជាបិតារបស់អ្នកហើយ ចូរបាចូលទៅថ្វាយបង្គំសុំកំណប់ទ្រព្យពីព្រះអង្គ, បើសិនជាបានកំណប់ទ្រព្យនោះមក បានឹងបានជាស្តេចចក្រលើផែនដីនេះ" ។ ព្រះរាហុលកុមារ ក៏ធ្វើតាមមាតា ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ឈ្វេងយល់ថា "ទ្រព្យសម្បត្តិជាលោកិយតែងនាំសត្វឱ្យលិចលង់ក្នុងវដ្តសង្សារ ដូច្នេះ គួរតថាគតចែកទ្រព្យជា

លោកុត្តរឱ្យកុមារនេះវិញចុះ” ។ ទ្រង់ត្រិះរិះដោយប្រាជ្ញាញាណយ៉ាងនេះ ហើយ ទ្រង់បញ្ជាឱ្យសារីបុត្ត បំបួសរាហុលកុមារជាសាមណេរ កុមាររាហុលនេះ បានបួសជាសាមណេរមុនជាងគេបង្អស់ក្នុងព្រះពុទ្ធសាសនា។

ដំណឹងព្រះរាហុលកុមារបួសនេះ ធ្វើឱ្យព្រះបាទសុទ្ធោទនៈជាព្រះ-អយ្យកា មានទុក្ខជាទម្ងន់ អត់ទ្រាំពុំបាន ក៏ចូលទៅគាល់ព្រះមានព្រះ-ភាគទូលសុំពរថា៖

**សាធុ ភន្តេ អយ្យា មាតាបិតូហិ អននុញ្ញាតំ បុត្តំ ន បព្វាជេយ្យុំ** ប្រែថា៖ “បពិត្រព្រះមានព្រះភាគដ៏ចំរើន សូមក្រាបទូលថា លោកម្ចាស់ទាំងឡាយ (ជាព្រះឧបជ្ឈាយ៍) មិនត្រូវបំបួសកុលបុត្រ ដែលមាតាបិតាមិនទាន់អនុញ្ញាតទេ” ។

ព្រះសាស្តាទ្រង់យល់ព្រមថ្វាយពរនេះ, ហេតុនោះ ពររបស់ព្រះ-អង្គ តាំងនៅជរាបដល់សព្វថ្ងៃនេះ ។

បន្ទាប់ពីនេះ យើងខ្ញុំ សូមដកស្រង់យកបាលីសម្រាប់សូត្រសុំបួសជា សាមណេរ ដូចតទៅ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# សាមណេរបព្វជ្ជាវិធី

កុលបុត្រដែលប្រាថ្នានឹងបួសជាសាមណេរ គប្បីកោរសក់ ពុកមាត់ ពុកចង្កា កាត់ក្រចក ឱ្យត្រឹមត្រូវតាមវិន័យបញ្ញត្តិ ហើយស្លៀកពាក់តាមបែបបទឃរាវាស ហើយកាន់យកគ្រឿងសក្ការបូជា មានទៀននិងធូបជាដើម ចូលទៅបូជាព្រះពុទ្ធរូបក្នុងខណ្ឌសីមា ធ្វើកាយបណាម វចីបណាម ដោយគោរព រួចហើយកាន់សំពត់កាសាវៈ បីទ្រចូលទៅកាន់សំណាក់ព្រះឧបជ្ឈាយ៍ ដាក់សំពត់កាសាវៈចុះក្បែរខ្លួន ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន រួចហើយក្រោកឈរទ្បើង ប្រណម្យអញ្ជលី សូត្រថា

**ឱកាស វន្ទាមិ ភន្តេ សព្វំ អបរាធំ ខមថ មេ ភន្តេ មយា កតំ បុញ្ញំ សាមិនា អនុមោទិតព្វំ សាមិនា កតំ បុញ្ញំ មយ្ហំ ទាតព្វំ សាធុ សាធុ អនុមោទាមិ**

ប្រែថាៈ សូមទានគោរព បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំលោកម្ចាស់ បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់អត់នូវទោស គឺសេចក្តីខុសទាំងពួងដល់ ខ្ញុំព្រះករុណា បុណ្យដែលខ្ញុំព្រះករុណា បានធ្វើហើយ សូមលោកម្ចាស់អនុមោទនា (ត្រេកអរតាម) ចុះ បុណ្យដែលលោកម្ចាស់បានធ្វើហើយ សូមលោកម្ចាស់ចែករំលែកឱ្យដល់ ខ្ញុំព្រះករុណាផង នឹងបាន សេចក្តីល្អ ញ៉ាំងប្រយោជន៍ឱ្យសម្រេច ខ្ញុំព្រះករុណា សូមទទួល

អនុមោទនា ( ត្រេកអរតាម ) ។

ហើយពោលដូច្នេះតទៅទៀតថា៖

**ឱកាស ការុញ្ញំ កត្វា បព្វជ្ជំ ទេថ មេ ភន្តេ ។**

ប្រែថា៖ សូមទានគោរព បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់មេត្តាប្រោស ធ្វើនូវសេចក្តីករុណា ហើយឱ្យនូវបព្វជ្ជាដល់ខ្ញុំព្រះករុណា ។

រួចហើយអង្គុយច្រហោងលើកដៃប្រណម្យពោលដូច្នេះថា៖

**អហំ ភន្តេ បព្វជ្ជំ យាចាមិ ។**

**ទុតិយម្បិ អហំ ភន្តេ បព្វជ្ជំ យាចាមិ ។**

**តតិយម្បិ អហំ ភន្តេ បព្វជ្ជំ យាចាមិ ។**

បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា សូមនូវបព្វជ្ជា ។

បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា សូមនូវបព្វជ្ជាជាគម្រប់ពីរដងផង ។

បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា សូមនូវបព្វជ្ជាជាគម្រប់បីដងផង ។

ហើយពោលដូច្នេះតទៅទៀត ៣ ដងថា៖

**សព្វទុក្ខ និស្សរណ និព្វាន សច្ឆិករណត្ថាយ ឥមំ កាសាវំ គហេត្វា បព្វាជេថ មំ ភន្តេ**

Websites: WatKhemaraRatanaram.org or WatKhmers.org

អនុកម្បំ ឧបាទាយ ។

ប្រែថា: បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់មេត្តាប្រោស ទទួលយកនូវសំពត់កាសាវៈនេះ ហើយធ្វើនូវសេចក្ដីអនុគ្រោះ បំបួសខ្ញុំព្រះករុណា ដើម្បីប្រយោជន៍ នឹងធ្វើឱ្យជាក់ច្បាស់នូវព្រះ-និព្វាន ដែលជាធម៌រលាស់នូវខ្លួនចេញចាកទុក្ខទាំងពួង ។

ព្រះឧបជ្ឈាយ៍ ត្រូវទទួលយក សំពត់កាសាវៈ អំពីបព្វជ្ជាបេក្ខ ហើយ បព្វជ្ជាបេក្ខ ត្រូវពោលដូច្នេះ ៣ ដងតទៅទៀតថា:

សព្វទុក្ខ និស្សរណ និព្វាន សច្ឆិករណត្ថាយ ឥមំ កាសាវំ ទត្វា បព្វាជេថ មំ ភន្តេ អនុកម្បំ ឧបាទាយ ។

ប្រែថា: បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់មេត្តាប្រោសឱ្យ នូវសំពត់កាសាវៈនុ៎ះ ដល់ខ្ញុំព្រះករុណា ហើយធ្វើនូវសេចក្ដីអនុ-គ្រោះ បំបួសខ្ញុំព្រះករុណា ដើម្បីប្រយោជន៍នឹងធ្វើឱ្យជាក់ច្បាស់ នូវព្រះនិព្វាន ដែលជាធម៌រលាស់នូវខ្លួនចេញចាកទុក្ខទាំងពួង ។

រួចហើយ ព្រះឧបជ្ឈាយ៍ ត្រូវប្រគល់សំពត់កាសាវៈនោះ ឱ្យបព្វជ្ជាបេក្ខ វិញ ហើយប្រាប់តចបញ្ចកកម្មដ្ឋានជាអនុលោមបដិលោមដោយបាលីថា:

កេសា លោមា នខា ទន្តា តចោ

តចោ ទន្តា នខា លោមា កេសា

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រែថា: សក់ រោម ក្រចក ធ្មេញ ស្បែក ស្បែក ធ្មេញ ក្រចក រោម សក់ ។

លុះរួចកិច្ចនេះហើយ បព្វជ្ជាបេក្ខគប្បីថ្វាយបង្គំ ៣ ដង ហើយក្រោកដើរទៅផ្លាស់សំលៀកបំពាក់យរាវាសចេញ ទ្រទ្រង់សំពត់កាសាវៈគឺស្លៀកស្បង់គ្រងចីវរឱ្យត្រឹមត្រូវតាមសេក្ខិយវត្ត ។ បន្ទាប់មក បព្វជ្ជាបេក្ខត្រូវកាន់គ្រឿងសក្ការៈមានទៀន ធូប ជាដើម ចូលទៅរកព្រះឧបជ្ឈាយ៍ ឬ បព្វជ្ជាចារ្យ ប្រគេនគ្រឿងសក្ការៈនោះទៅលោកហើយ ក្រោកឈរប្រណមអញ្ជលីសូត្រថា:

**ឱកាស វន្ទាមិ ភន្តេ ។ ល ។ សាធុ សាធុ អនុមោទាមិ ។** (ប្រែដូចមុន) រួចហើយពោលដូច្នេះតទៅទៀតថា:

**ឱកាស ការុញ្ញំ កត្វា តិសរណេន សហ សីលានិ ទេថ មេ ភន្តេ ។**

ប្រែថា: សូមទានគោរព បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់មេត្តាប្រោស ធ្វើនូវសេចក្ដីករុណា ឱ្យនូវសីលទាំងឡាយព្រមទាំងព្រះត្រៃសរណគមន៍ ដល់ខ្ញុំព្រះករុណា ។

ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើងពោលដូច្នេះថា:

**អហំ ភន្តេ សរណសីលំ យាចាមិ** បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាសូមនូវព្រះត្រៃសរណគមន៍ និងសីល ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ទុតិយម្បិ
អហំ ភន្តេ សរណសីលំ យាចាមិ បពិត្រ
តតិយម្បិ

លោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា សូមនូវព្រះត្រៃសរណគមន៍និងសីល ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង ។

ហើយបព្វជ្ជាបេក្ខ តាំង នមោ បីដងថា:

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

ប្រែថា: វីកិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា សូមមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឯងឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

ព្រះឧបជ្ឈាយ៍តាំង នមោ បីដងហើយពោលថា:

**យមហំ វទាមិ តំ វទេហិ** យើងពោលនូវពាក្យឯណា អ្នកចូរពោលនូវពាក្យនោះ ។ បព្វជ្ជាបេក្ខត្រូវទទួលថា:

**អាម ភន្តេ** ករុណាលោកម្ចាស់ (ខ្ញុំព្រះករុណា នឹងពោលតាម) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះឧបជ្ឈាយ៍ ឬ បព្វជ្ជាចារ្យ ឱ្យព្រះត្រៃសរណគមន៍ថា៖

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរលឹក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ទីរលឹក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរលឹក ។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹង ទីរលឹក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹង ទីរលឹក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹង ទីរលឹក ជាគម្រប់ពីរដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹង ទីរលឹក ជាគម្រប់បីដងផង ។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹង ទីរលឹក ជាគម្រប់បីដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់

Websites: WatKhemaraRatanaram.org or WatKhmers.org

នូវព្រះសង្ឃជាទីពឹងទីរលឹក ជាគម្រប់បីដងផង ។

ឯវិធីដែលនឹងឱ្យព្រះត្រៃសរណគមន៍នេះ ឱ្យជាអនុនាសិកន្ត ជាឯកសម្ពន្ធ ដូច្នេះក៏បាន នឹងឱ្យជា មការន្ត ក៏បាន ឬ នឹងឱ្យទាំងអនុនាសិកន្ត និង មការន្ត ទាំងពីរយ៉ាងក៏បាន ។

វិធីឱ្យជាមការន្តនោះ ត្រូវឱ្យមួយបទម្តង ៗ ដូច្នេះថា:

ពុទ្ធម សរណម គច្ឆាមិ

ធម្មម សរណម គច្ឆាមិ

សង្ឃម សរណម គច្ឆាមិ

ទុតិយម្បិ ពុទ្ធម សរណម គច្ឆាមិ

ទុតិយម្បិ ធម្មម សរណម គច្ឆាមិ

ទុតិយម្បិ សង្ឃម សរណម គច្ឆាមិ

តតិយម្បិ ពុទ្ធម សរណម គច្ឆាមិ

តតិយម្បិ ធម្មម សរណម គច្ឆាមិ

តតិយម្បិ សង្ឃម សរណម គច្ឆាមិ

(ប្រែថាដូចមុន) ហើយលោកពោលថា:

តិសរណគមនំ នេះជាកិច្ចដល់នូវព្រះត្រៃសរណគមន៍ ឬថា តិសរណគ្គហណំ បរិបុណ្ណំ កិរិយាកាន់យក គឺទទួលនូវ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះត្រៃសរណគមន៍ បរិបូណ៌ហើយ ។ សាមណេរត្រូវទទួលថា អាម ភន្តេ ។ ហើយក្រាបចុះម្តង រួចទទួលសិក្ខាបទ ១០ តទៅទៀតថា:

១- បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ
២- អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ
៣- អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ
៤- មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ
៥- សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ
៦- វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ
៧- នច្ចគីតវាទិតវិសូកទស្សនា វេរមណី សិក្ខាបទំ សមាទិយាមិ
៨- មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋា-នា វេរមណី សិក្ខាបទំ សមាទិយាមិ
៩- ឧច្ចាសយន មហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ
១០- ជាតរូបរជតប្បដិគ្គហណា វេរមណី សិក្ខាបទំ សមាទិយាមិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បន្ទាប់មក សាមណេរ ត្រូវទទួលតាមលោកទៀត ៣ ដង

ឥមានិ ទស សិក្ខាបទានិ សមាទិយាមិ ។

ក្រាបថ្វាយបង្គំម្តង ក្រោកឈរ ប្រណម្យអញ្ជលីសូត្រថា៖

វន្ទាមិ ភន្តេ សព្វំ អបរាធំ ។ ល ។ សាធុ សាធុ អនុមោទាមិ ។ ( ក្រាបថ្វាយបង្គំ ៣ ដង )

វិធីបួសជាសាមណេរចប់តែប៉ុណ្ណេះ ។

បន្ទាប់មក គប្បីសុំនិស្ស័យ ឯបាលីសុំនិស្ស័យនោះមានដូចតទៅ៖

## បាលីសុំនិស្ស័យឧបជ្ឈាយ៍

កុលបុត្រ បានបួសជាសាមណេរពេញលក្ខណៈ ដូចបានធ្វើរួចមកហើយនោះ តពីនេះទៅ គប្បីសុំនិស្ស័យពីព្រះឧបជ្ឈាយ៍ ។

រីឯកិច្ចសុំនិស្ស័យ គឺសាមណេរ ត្រូវមានគ្រឿងសក្ការៈ ប្រគេនព្រះឧបជ្ឈាយ៍ ប្រណម្យអញ្ជលីសូត្រថា៖

ឱកាស វន្ទាមិ ភន្តេ ។ ល ។ សាធុ សាធុ អនុមោទាមិ

ឱកាស ការុញ្ញំ កត្វា និស្សយំ ទេថ មេ ភន្តេ ។

អង្គុយចុះផ្គងអញ្ជលីសូត្រថា៖

អហំ ភន្តេ និស្សយំ យាចាមិ ។

ទុតិយម្បិ អហំ ភន្តេ និស្សយំ យាចាមិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## តតិយម្បិ អហំ ភន្តេ និស្សយំ យាចាមិ ។

ក្រាបសិរសាចុះ សូត្រថា:

**ឧបជ្ឈាយោ មេ ភន្តេ ហោហិ**

ព្រះឧបជ្ឈាយ៍ លោកពោលតបថា **សាធុ** ឬថា **លហុ** ថា **ឱបាយិកំ** ឬថា **បដិរូបំ** ឬក៏ **បាសាទិកេន សម្បាទេហិ** ទាំង ៥ បទនេះ ណាមួយ ស្រេចលើព្រះទ័យលោក ។ សាមណេរ គប្បីទទួលថា:

**ឧកាស សម្បដិច្ឆាមិ** ។ លោកពោលពីរដងទៀត គប្បីទទួលត្រឹមតែថា **សម្បដិច្ឆាមិ** ។

បន្ទាប់មក សាមណេរងើបសិរសាឡើងប្រណម្យអញ្ជលី សូត្រ ៣ ដងឱ្យខ្លាំង ៗ ថា:

**អជ្ជតគ្គេទានិ ថេរោ មយ្ហំ ភារោ អហំបិ ថេរស្ស ភារោ** ។

រួចហើយថ្វាយបង្គំ ៣ ដង ។ ឈ្មោះថាចប់វិធីយកវត្តតែប៉ុណ្ណោះ ។ កិច្ចបព្វជ្ជាជាសាមណេរ ក៏ចប់ត្រឹមនេះដែរ បន្ទាប់ពីនេះទៅ យើងខ្ញុំសូមរៀបរាប់អំពីវិន័យសម្រាប់សិក្សាម្តង ។

(ចាកបព្វជ្ជាខន្ធក សង្ខេប)

# សាមណេរវិន័យ

កុលបុត្រដែលនឹងបួសជាសាមណេរ គប្បីសិក្សាវិន័យឱ្យចេះដឹងជាមុន ។ ឯវិន័យដែលសាមណេរ ត្រូវសិក្សានោះមាន ៣០ គឺសិក្ខាបទ ១០ ទណ្ឌកម្ម ១០ នាសនង្គៈ ១០ រួមត្រូវជា ៣០ គត់ ។

សិក្ខាបទ គឺជាធម៌ដែលសាមណេរត្រូវសិក្សា ។ ទណ្ឌកម្ម គឺសេចក្ដីខុសដែលសាមណេរធ្វើឱ្យកន្លងហើយ ភិក្ខុត្រូវធ្វើទោសមានឱ្យដងទឹកជាដើម ដើម្បីឱ្យរាងចាល ។ ចំណែក នាសនង្គៈ គឺជាអង្គដែលជាហេតុនឹងត្រូវឱ្យសាមណេរវិនាស គឺឱ្យសឹកចេញ ។

## សិក្ខាបទ ១០

១- *បាណាតិបាតា វេរមណី* ចេតនាជាហេតុវៀរចាកធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

២- *អទិន្នាទានា វេរមណី* ចេតនាជាហេតុវៀរចាកកិរិយាកាន់យកវត្ថុដែលគេមិនបានឱ្យដោយកាយឬដោយវាចា ។

៣- *អព្រហ្មចរិយា វេរមណី* ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តិនូវធម៌មិនប្រសើរ គឺសេពមេថុនធម្ម ។

៤- *មុសាវាទា វេរមណី* ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥- *សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី* ចេតនា

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរា និងមេរ័យ ។

៦- វិកាលភោជនា វេរមណី ចេតនាជាហេតុវៀរចាក កិរិយាបរិភោគនូវភោជនាហារ ក្នុងកាលខុស ។

៧- នច្ចគីតវាទិតវិសូកទស្សនា វេរមណី ចេតនាជាហេតុវៀរចាក កិរិយារាំ-ច្រៀង-ប្រគំ និងមើលល្បែងដែលជាសត្រូវដល់កុសលធម៌ ។

៨- មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី ចេតនាជាហេតុវៀរចាក កិរិយាទ្រទ្រង់-ប្រដាប់ និងការតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និង គ្រឿងលាបផ្សេង ៗ ។

៩- ឧច្ចាសយន មហាសយនា វេរមណី ចេតនាជាហេតុវៀរចាក ទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។

១០- ជាតរូបរជតប្បដិគ្គហណា វេរវណី ចេតនាជាហេតុវៀរចាក កិរិយាទទួលកាន់យកនូវមាស និងប្រាក់ដោយខ្លួនឯង ឬ ប្រើអ្នកដទៃឱ្យទទួលកាន់យក ហើយត្រេកអរចំពោះមាស និង ប្រាក់នោះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## ទណ្ឌកម្ម ១០

១- វិកាលភោជី ហោតិ សាមណេរបរិភោគនូវភោជ-នាហារ ក្នុងកាលខុស ។

២- នច្ចាទិវិសូកទស្សិកោ ហោតិ សាមណេររាំ-ច្រៀងប្រគំ និងមើលល្បែង ដែលជាសត្រូវដល់កុសលធម៌ ។

៣- មាលាទិធារណាទិកោ ហោតិ សាមណេរទ្រទ្រង់ ប្រដាប់ និង តាក់តែងទ្រទ្រង់រាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និង គ្រឿងលាបផ្សេងៗ ។

៤- ឧច្ចាសយនាទិកោ ហោតិ សាមណេរដេកឬអង្គុយលើទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។

៥- ជាតរូបរជតប្បដិគ្គណ្ហាកោ ហោតិ សាមណេរ ទទួលកាន់យកនូវមាស និងប្រាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យទទួលកាន់យក ហើយត្រេកអរចំពោះមាស និងប្រាក់នោះ ។

៦- ភិក្ខូនំ អលាភាយ បរិសក្កតិ សាមណេរព្យាយាមដើម្បីនឹងឱ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ ។

៧- ភិក្ខូនំ អនត្ថាយ បរិសក្កតិ សាមណេរព្យាយាមដើម្បីមិនឱ្យជាប្រយោជន៍ដល់ភិក្ខុទាំងឡាយ ។

៨- ភិក្ខូនំ អនាវាសាយ បរិសក្កតិ សាមណេរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្យាយាម ដើម្បីនឹងមិនឱ្យភិក្ខុទាំងឡាយបាននូវទីលំនៅ ។

៩- ភិក្ខូ អក្កោសតិ បរិភាសតិ សាមណេរជេរប្រទេច នូវភិក្ខុទាំងឡាយ ។

១០- ភិក្ខូ ភិក្ខូហិ ភេទេតិ សាមណេរញុាំងភិក្ខុទាំង-ឡាយឱ្យបែកចាកភិក្ខុទាំងឡាយ ។

## នាសនង្គៈ ១០

១- បាណាតិបាតី ហោតិ សាមណេរធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

២- អទិន្នាទាយី ហោតិ សាមណេរកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយឬដោយវាចា ។

៣- អព្រហ្មចារី ហោតិ សាមណេរប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

៤- មុសាវាទី ហោតិ សាមណេរពោលនូវពាក្យកុហក ។

៥- មជ្ជបាយី ហោតិ សាមណេរផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

៦- ពុទ្ធស្ស អវណ្ណំ ភាសតិ សាមណេរពោលតិះដៀលនូវព្រះសម្មាសម្ពុទ្ធ ។

៧- ធម្មស្ស អវណ្ណំ ភាសតិ សាមណេរពោលតិះដៀល

Websites: WatKhemaraRatanaram.org or WatKhmers.org

នូវព្រះធម៌ ។

៨- សង្ឃស្ស អវណ្ណំ ភាសតិ សាមណេរពោលតិះដៀល នូវព្រះសង្ឃ ។

៩- មិច្ឆាទិដ្ឋិកោ ហោតិ សាមណេរមានទិដ្ឋិខុស ។

១០- ភិក្ខុនីទូសកោ ហោតិ សាមណេរប្រទូស្តនឹងនាងភិក្ខុនី ។

## អង្គសិក្ខាបទ

សាមណេរ ប្រព្រឹត្តកន្លងសិក្ខាបទណាមួយ លុះតែព្រមគ្រប់អង្គក្នុងសិក្ខាបទនោះ ទើបឈ្មោះថាកន្លង បើមិនព្រមដោយអង្គទេ មិនឈ្មោះថាកន្លងឡើយ ។ ឯអង្គរបស់សិក្ខាបទនោះ មានចែកដូចតទៅ៖

### បាណាតិបាតៈ មានអង្គ ៥

១- បាណោ សត្វមានជីវិត

២- បាណសញ្ញិតា សេចក្តីសំគាល់ថា សត្វមានជីវិត

៣- វធកចិត្តំ គិតនឹងសម្លាប់

៤- ឧបក្កមោ ព្យាយាមនឹងសម្លាប់

៥- តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

### អទិន្នាទានៈ មានអង្គ ៥

១- បរបរិគ្គហិតំ ទ្រព្យដែលម្ចាស់របស់គេហួងហែងរក្សា

Websites: WatKhemaraRatanaram.org or WatKhmers.org

២- បរបរិគ្គហិតសញ្ញិតា សេចក្ដីដឹងថាទ្រព្យមានម្ចាស់គេហួងហែងរក្សា

៣- ថេយ្យចិត្ត គិតនឹងលួច

៤- ឧបក្កមោ ព្យាយាមនឹងលួច

៥- តេន ហរណំ លួចបានមកដោយព្យាយាមនោះ ។

## អព្រហ្មចរិយៈ មានអង្គ ៤

១- ភេទនវត្ថុ វត្ថុជាទីទំលាយនូវសីល គឺក្នុងទ្វារទាំង ៣០ ទ្វារណាមួយ ។

២- សេវនចិត្តំ គិតនឹងសេព

៣- តជ្ជោ វាយាមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ ។

៤- មគ្គេន មគ្គប្បដិបាទនំ ញ៉ាំងមគ្គនឹងមគ្គឱ្យដល់គ្នា ។

## មុសាវាទៈ មានអង្គ ៤

១- អតថំវត្ថុ វត្ថុមិនពិត

២- វិសំវាទនចិត្តំ គិតនឹងពោលឱ្យខុស

៣- តជ្ជោ វាយាមោ ព្យាយាមនឹងពោលឱ្យខុសនោះ

៤- បរស្ស តទត្ថវិជាននំ ញ៉ាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្ដីនោះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## សុរាមេរយៈ មានអង្គ ៤

១- មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរានឹងមេរ័យ ។

២- ធាតុកម្យតាចិត្តំ ចិត្តប្រាថ្នាដើម្បីនឹងផឹក ។

៣- តជ្ជោ វាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ។

៤- តស្ស ធានំ បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ ។

## វិកាលភោជនៈ មានអង្គ ៣

១- វិកាលោ កាលខុស គឺព្រះអាទិត្យជ្រេទៅហើយដរាបទល់នឹងអរុណរះ

២- យាវកាលិកំ របស់ដែលគួរបរិភោគបានក្នុងកាលគឺតាំងពីអរុណរះឡើងដល់ថ្ងៃត្រង់

៣- អជ្ឈោហរណំ បានលេបចូលទៅក្នុងបំពង់ក

## នច្ចគីតៈ មានអង្គ ៣

១- នច្ចគីតាទិ ការល្បែងមានរាំនិងច្រៀងជាដើម

២- កត្តុកម្យតាចិត្តំ ចិត្តប្រាថ្នាដើម្បីនឹងធ្វើ

៣- សុតទស្សនត្ថាយ គមនំ ទៅដើម្បីនឹងស្តាប់ឬមើលហើយបានស្តាប់ឬមើល ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**មាលា មានអង្គ ៣**

១- **មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើម

២- **ធារណាច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង

៣- **តស្ស ធារណំ** បានប្រដាប់តាក់តែងនូវវត្ថុសំរាប់ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ ។

**ឧច្ចាសយនៈ មានអង្គ ៣**

១- **ឧច្ចាសយនមហាសយនំ** ទីដេកទីអង្គុយដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ

២- **បរិភោគចិត្តំ** គិតនឹងដេក ឬ អង្គុយ

៣- **បរិភោគករណំ** បានដេក ឬ អង្គុយ ។

**ជាតរូបៈ មានអង្គ ៣**

១- **ជាតរូបរជតំ** មាសឬប្រាក់ ជាអកប្បិភណ្ឌ

២- **អត្តុទ្ទិសតា** ចំពោះជារបស់ខ្លួន

៣- **បដិគ្គណ្ហាទិ** បានទទួលកាន់យកដោយខ្លួនឯង ឬប្រើគេឱ្យទទួលកាន់យកទុកដាក់ឱ្យ ហើយត្រេកអរចំពោះមាស ឬប្រាក់នោះ ដោយឧបាយឯណានីមួយ ។

សាមណេរ កាលបានសិក្សាចាំស្ទាត់ហើយ គប្បីវិនិច្ឆ័យ ពិចារណាកាត់សេចក្តីដោយខ្លួនឯងថា សិក្ខាបទនោះៗ បរិសុទ្ធ សៅហ្មង

ដាច់ ពពាល ឬយ៉ាងណាៗ តាមអង្គសិក្ខាបទនោះចុះ ។

ម្យ៉ាងទៀត លោកឱ្យវិនិច្ឆ័យសិក្ខាបទកន្លង ឬ បរិសុទ្ធទៅតាមបយោគ ដែលមានសំដែងដូចតទៅ ៖

## បយោគ

សេចក្តីព្យាយាមនឹងប្រព្រឹត្តធ្វើឱ្យកន្លងសិក្ខាបទ ឈ្មោះថាបយោគ ។ នោះមាន ២ គឺ សាហត្ថិកប្បយោគ១ អាណត្តិកប្បយោគ១ ។ ការធ្វើឱ្យកន្លងដោយខ្លួនឯង ហៅថា សាហត្ថិកប្បយោគ, ប្រើអ្នកដទៃឱ្យធ្វើហៅថា អាណត្តិកប្បយោគ ។

ក្នុងសិក្ខាបទទាំង ១០ នោះ

សិក្ខាបទទី ៣ គឺ អព្រហ្មចរិយៈ

សិក្ខាបទទី ៤ គឺ មុសាវាទៈ

សិក្ខាបទទី ៥ គឺ សុរាមេរយៈ

សិក្ខាបទទី ៦ គឺ វិកាលភោជនៈ

សិក្ខាបទទី ៧ គឺ នច្ចគីតៈ

សិក្ខាបទទី ៨ គឺ មាលា និង

សិក្ខាបទទី៩ គឺ ឧច្ចាសយនៈ ទាំង ៧ សិក្ខាបទនេះ ជា សាហត្ថិកប្បយោគ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សិក្ខាបទទី ១ គឺ បាណាតិបាតៈ

សិក្ខាបទទី ២ គឺ អទិន្នាទានៈ និង

សិក្ខាបទទ ១០ គឺ ជាតរូបៈ ទាំង ៣ សិក្ខាបទនេះជា **អាណត្តិកប្បយោគ** ។

ម៉្យាងទៀត សិក្ខាបទទាំង ១០ នោះ លោកចែកចេញជា ២ ពួក គឺ **សាណត្តិកៈ** ពួក ១ ជា **អនាណត្តិកៈ** ពួក ១ ។

សិក្ខាបទ ឯណាដែលជា **អាណត្តិកប្បយោគ** សិក្ខាបទនោះជា **សាណត្តិកៈ** ព្រោះអ្នករក្សាធ្វើដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យធ្វើក្តី ឈ្មោះថាកន្លងដូចគ្នា ។

សិក្ខាបទ ឯណាដែលជា **សាហត្ថិកប្បយោគ** សិក្ខាបទនោះជា **អនាណត្តិកៈ** ព្រោះអ្នករក្សាធ្វើដោយខ្លួនឯង ទើបឈ្មោះថាកន្លង បើប្រើអ្នកដទៃឱ្យធ្វើ នោះមិនបានឈ្មោះថា កន្លងទេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## កិច្ចនៃទណ្ឌកម្ម

សាមណេរធ្វើខុស មានទោសមិនដល់នាសនា ទ្រង់ប្រទានព្រះ-ពុទ្ធានុញ្ញាតឱ្យដាក់ទណ្ឌកម្ម ។

ការដាក់ទណ្ឌកម្មនោះ បានដល់ការឃាត់ឃាំងហាមមិនឱ្យចូល ហាមមិនឱ្យចេញ ដូចជាសាមណេរធ្លាប់នៅឬធ្លាប់ទៅទីណា មិនឱ្យចូលទៅទីនោះ តែលោកហាមមិនឱ្យឃាត់ឃាំងរហូតអស់អារាមទាំងមូល ។ ការហាមនេះ ហៅថា ***អាវរណកម្ម*** ។

ព្រះធម្មសង្គាហកត្ថេរទាំងឡាយ កាលសង្គាយនា លោកបង្គាប់ឱ្យដាក់ទណ្ឌកម្មដោយកិច្ចគឺឱ្យដងទឹក រកឧស ជញ្ជូនដីខ្សាច់ ជាដើម ។

## បាលីសុំទណ្ឌកម្ម

សាមណេរ បើត្រូវទោសគួរដល់ទណ្ឌកម្មហើយ គប្បីចូលទៅសូមទណ្ឌកម្មក្នុងសំណាក់ឧបជ្ឈាយ៍ ឬ អាចារ្យដោយសូត្រពោល ៣ ដង ដូច្នេះថាៈ

***លភេយ្យាហំ ភន្តេ ទណ្ឌកម្មំ អាយតិំ សំវរំ អាបជ្ជិស្សាមិ*** ប្រែថាៈ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាត្រូវបាននូវទណ្ឌកម្ម ខ្ញុំព្រះករុណានឹងដល់នូវសេចក្ដីសង្រួម គឺថា នឹងប្រព្រឹត្តឱ្យល្អតទៅមុខទៀត ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះឧបជ្ឈាយ៍ ឬ អាចារ្យត្រូវដាក់ទណ្ឌកម្មឱ្យសាមណេរនោះ តាមទោសកំហុស ។ បើបានធ្វើទណ្ឌកម្មរួចស្រេចហើយ សាមណេរនោះក៏ឈ្មោះថា បានតាំងនៅក្នុងសេចក្ដីបរិសុទ្ធិដូចប្រក្រតី ។

## កិច្ចនៃនាសនង្គៈ

កិច្ចដែលនឹងឱ្យសាមណេរវិនាសនោះ គឺក្នុងនាសនង្គៈទាំង ១០ ។ នាសនង្គៈ ៥ ខាងដើម នាសនង្គៈឯណាមួយ ដែលសាមណេរធ្វើឱ្យដាច់ហើយ, សរណគមន៍ក្ដី សេចក្ដីកាន់យកនូវព្រះឧបជ្ឈាយ៍ក្ដី ទីលំនៅដែលខ្លួនធ្លាប់នៅនោះក្ដី សង្ឃលាភដែលខ្លួនត្រូវបានក្ដី ក៏ដាច់អស់ហើយនៅសល់តែភេទម៉្យាង ដោយហេតុស្លៀកពាក់ដណ្ដប់កាសាវៈប៉ុណ្ណោះ ។ ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវឱ្យសាមណេរនោះសឹកចេញក្នុងខណៈដែលប្រព្រឹត្ត ធ្វើឱ្យកន្លងសីលនោះ ។

បើសាមណេរនោះជាមនុស្សអាក្រក់ ច្រឡំពេញដោយទោសក្នុងសីលទាំង ៥ ខាងដើមក្រៃពេកណាស់ ពោលប្រដៅគ្រប់ ៣ ដងហើយនៅតែមិនស្ដាល់ មិនមានប្រាថ្នានឹងតាំងនៅក្នុងការសង្រួមតទៅទៀតទេ, ព្រះឧបជ្ឈាយ៍ ឬអាចារ្យ ត្រូវអបលោកន៍ប្រាប់សង្ឃឱ្យដឹងហើយឱ្យសឹកចេញ បើមានប្រាថ្នានឹងចង់បួសវិញ ក៏គប្បីអបលោកន៍ប្រាប់សង្ឃឱ្យដឹងហើយឱ្យបួសទៀតចុះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ម្យ៉ាងទៀត បើសាមណេរឱ្យកន្លងសិក្ខាបទណាមួយហើយ ដឹងខ្លួនភ្លាមមួយរំពេច ហើយមានប្រាថ្នានឹងតាំងនៅក្នុងសេចក្ដីសង្រួមតទៅទៀត ព្រះឧបជ្ឈាយ៍ឬអាចារ្យកុំគប្បីឱ្យសាមណេរនោះសឹកឡើយ គប្បីឱ្យទទួលព្រះត្រៃសរណគមន៍ នឹងកាន់យកនូវព្រះឧបជ្ឈាយ៍ទៀតចុះ ឬនឹងឱ្យសមាទានសិក្ខាបទជាថ្មីទៀត ក៏រឹងរឹតតែប្រសើរ ។

បើសាមណេរធ្វើឱ្យកន្លងនាសនង្គៈ ទី ៦ - ៧ - ៨ ព្រះឧបជ្ឈាយ៍ ឬអាចារ្យត្រូវសំដែងទោសប្រាប់សាមណេរ កុំឱ្យតិះដៀលព្រះរតនត្រ័យតទៅទៀត នឹងសំដែងអំពីទោសនៃការតិះដៀលនោះ បើបានពោលហាមហើយ សាមណេរនោះលះបង់ទិដ្ឋិនោះចេញ ក៏គប្បីដាក់ទណ្ឌកម្មរួចហើយ ឱ្យសំដែងទោសក្នុងកណ្ដាលជំនុំសង្ឃដូច្នេះថា:

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យោហំ ភន្តេ ឯវំ អកាសិ តស្ស មេ អច្ចយំ អច្ចយតោ បដិគ្គណ្ហាថ អាយតិ សំវរេយ្យាមិ ។

បពិត្រលោកម្ចាស់ដ៏ចំរើន ទោសគឺសេចក្ដីខុស ប្រព្រឹត្តកន្លងគ្របសង្កត់ហើយ នូវខ្ញុំព្រះករុណា ព្រោះជាមនុស្សពាលពេកណាស់ ជាមនុស្សវង្វេងពេកណាស់ ជាមនុស្សមិនឈ្លាសពេកណាស់ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា ឯណាបានពោល

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយនូវពាក្យតិះដៀលព្រះរតនត្រ័យយ៉ាងនេះ សូមលោកម្ចាស់មេត្តាប្រោសអត់នូវទោសគឺសេចក្តីខុស ដល់ខ្ញុំព្រះករុណាជាអ្នកមានទោសខុសនោះ ខ្ញុំព្រះករុណា គប្បីសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អ តទៅខាងមុខទៀត ។

លុះសំដែងទោសដូច្នេះរួចហើយ ត្រូវឱ្យព្រះត្រៃសរណគមន៍ និងសីលជាថ្មីទៀត ។ បើហាមប្រាមហើយ មិនលះបង់ទិដ្ឋិនោះចោលទេ គប្បីឱ្យសឹកចេញ ។

បើសាមណេរមានទោសខុសក្នុងនាសនង្គៈទី ៩ ត្រូវព្រះឧបជ្ឈាយ៍ ឬ អាចារ្យ សំដែងទោសអំពីមិច្ឆាទិដ្ឋិប្រាប់សាមណេរនោះ ហើយហាមប្រាមឱ្យលះបង់ទិដ្ឋិនោះចេញ ។ បើសាមណេរនោះលះបង់ហើយគប្បីដាក់ទណ្ឌកម្មរួចឱ្យសំដែងទោសក្នុងកណ្តាលជំនុំសង្ឃថា:

**អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យោហំ ភន្តេ ឯវំ អភាសិ តស្ស មេ អច្ចយំ អច្ចយតោ បដិគ្គណ្ហាថ អាយតិ សំវរេយ្យាមិ ។**

បពិត្រលោកម្ចាស់ដ៏ចំរើន ទោសគឺសេចក្តីខុសប្រព្រឹត្តកន្លងគ្របសង្កត់ហើយ នូវខ្ញុំព្រះករុណា ព្រោះជាមនុស្សពាលពេកណាស់ ជាមនុស្សវង្វេងពេកណាស់ ជាមនុស្សមិនឈ្លាសពេក

Websites: WatKhemaraRatanaram.org or WatKhmers.org

ណាស់ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា ឯណាជាមនុស្សឃើញខុសយ៉ាងនេះ សូមលោកម្ចាស់ មេត្តាប្រោសអត់នូវទោស គឺសេចក្តីខុសដល់ខ្ញុំព្រះករុណា ជាអ្នកមានទោសខុសនោះ ខ្ញុំព្រះករុណាគប្បីសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អ តទៅខាងមុខទៀត ។

លុះសំដែងទោសដូច្នេះហើយ ត្រូវឱ្យសរណគមន៍ និងសីលជាថ្មី ។ បើហាមហើយ នៅតែមិនលះបង់ គប្បីឱ្យសាមណេរនោះសឹកចេញ ។

បើសាមណេរកាន់យកដោយវិបរិតខុសចាកពុទ្ធវចនាធិប្បាយ ភិក្ខុទាំងឡាយទូន្មានមិនស្តាប់ សាមណេរនោះមិនឈ្មោះថា ដល់បារាជិកទេ តែថាព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវធ្វើកណ្តកនាសនា គឺឱ្យសឹកចេញ បើមានប្រាថ្នានឹងបួសវិញ គប្បីអបលោកន៍ប្រាប់សង្ឃហើយ ឱ្យបួសចុះ។

បើសាមណេរមានទោសខុសក្នុងនាសនង្គៈទី ១០ ព្រះឧបជ្ឈាយ៍ឬ អាចារ្យ ផ្សឹកសាមណេរនោះចេញ បើទុកជាមានប្រាថ្នានឹងបួសវិញក៏មិនត្រូវបំបួសទៀតទេ ។ តែសិក្ខាបទ ១០ នេះ ក្នុងកាលឥឡូវនេះ មិនមានទេ ព្រោះមិនមានភិក្ខុនី ។

សរុបសេចក្តីមក កិច្ចដែលឱ្យសាមណេរវិនាសនោះមាន ៣ យ៉ាងគឺ:

១- *សំវាសនាសនា* វិនាសទីកន្លែងខានបាននៅជាមួយសង្ឃ ឬត្រូវថយឱ្យផុតពីទីកន្លែងរបស់សង្ឃ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

២- *លិង្គនាសនា* វិនាសចាកភេទ គឺឱ្យសឹកចេញ

៣- *ទណ្ឌកម្មនាសនា* វិនាសដោយត្រូវទណ្ឌកម្ម មាន មិនឱ្យដេកនៅរួមនឹងភិក្ខុអស់ពីរបីរាត្រីជាដើម ។

## សេខិយវត្ត

វត្តដែលសាមណេរគប្បីសិក្សាហៅថា *សេខិយវត្តៗ* នោះចាត់ជា ៤ ពួកគឺៈ ពួកទី ១ ឈ្មោះ *សារូប*, ពួកទី ២ ឈ្មោះ *ភោជនប្បដិសំយុត្ត*, ពួកទី ៣ ឈ្មោះ ធម្មទេសនាបដិសំយុត្ត, ពួកទី ៤ ឈ្មោះ *បកិណ្ណក* ។

### សារូបទី ១ មាន ២៦ គឺ

១- *បរិមណ្ឌលនិវាសន* សាមណេរគប្បីសិក្សាថា អញនឹងស្លៀកឱ្យជាបរិមណ្ឌល គឺខាងក្រោម គ្របក្បាលជង្គង់ចុះទៅ ៨ ធ្នាប់ ខាងលើបិទមណ្ឌលផ្ចិត ខាងមុខ-ក្រោយត្រឹមស្មើគ្នា ។

២- *បរិមណ្ឌលបារុបន* សាមណេរគប្បីសិក្សាថា អញនឹងគ្រងចីពរឱ្យជាមណ្ឌល គឺខាងក្រោមខើចឡើងលើស្បង់ ៤ ធ្នាប់ ខាងលើបិទបាំងកែងដៃខាងឆ្វេងឱ្យរៀបរយមិនឱ្យរយីករយាក ។

៣- *សុប្បដិច្ឆន្នោ អន្តរឃរេ គមន* សាមណេរគប្បីសិក្សាថា អញនឹងបិទបាំងកាយឱ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៤- សុប្បដិច្ឆន្នោ អន្តរឃរេ និសីទនៈ សាមណេរ គប្បីសិក្សាថា អញបិទបាំងកាយឱ្យល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ។

៥- សុសំវុតោ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងសង្រួមប្រយ័ត្នដោយល្អ គឺមិនបានរលាស់ដៃជើង ដើរទៅក្នុងចន្លោះផ្ទះ ។

៦- សុសំវុតោ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងសង្រួមប្រយ័ត្នដោយល្អ គឺមិនបានរលាស់ដៃជើង អង្គុយនៅក្នុងចន្លោះផ្ទះ ។

៧- ឱក្ខិត្តចក្ខុ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងសំឡឹងខាងក្រោម គឺក្រឡេកមើលប្រមាណមួយជួរនឹម ដើរទៅក្នុងចន្លោះផ្ទះ ។

៨- ឱក្ខិត្តចក្ខុ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងសំឡឹងខាងក្រោម គឺក្រឡេកមើលប្រមាណមួយជួរនឹម អង្គុយនៅក្នុងចន្លោះផ្ទះ ។

៩- ន ឧក្ខិត្តកាយ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនសើយចីវរលាត់កញ្ជើញ ដើរទៅក្នុងចន្លោះផ្ទះ។

១០- ន ឧក្ខិត្តកាយ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនសើយចីវរលាត់កញ្ជើញ អង្គុយក្នុងចន្លោះផ្ទះ។

Websites: WatKhemaraRatanaram.org or WatKhmers.org

១១- ន ឧជ្ជុគ្គិកាយ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ។

១២- ន ឧជ្ជុគ្គិកាយ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនសើចខ្លាំង អង្គុយនៅក្នុងចន្លោះផ្ទះ ។

១៣- អប្បសទ្ទោ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងនិយាយសំឡេងតិចៗ ដើរនៅក្នុងចន្លោះផ្ទះ ។

១៤- អប្បសទ្ទោ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងនិយាយសំឡេងតិចៗ អង្គុយនៅក្នុងចន្លោះផ្ទះ ។

១៥- ន កាយប្បចាលកំ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនគ្រវែងកាយ ដើរទៅក្នុងចន្លោះផ្ទះ ។

១៦- ន កាយប្បចាលកំ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនគ្រវែងកាយ អង្គុយនៅក្នុងចន្លោះផ្ទះ ។

១៧- ន ពាហុប្បចាលកំ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនបង់ហោយ ដើរទៅក្នុងចន្លោះផ្ទះ ។

១៨- ន ពាហុប្បចាលកំ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនយោលដៃ អង្គុយនៅក្នុងចន្លោះផ្ទះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

១៩- ន សីសប្បចាលកំ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនអង្រួនក្បាល ដើរទៅក្នុងចន្លោះផ្ទះ ។

២០- ន សីសប្បចាលកំ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនអង្រួនក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ។

២១- ន ខម្ភកតោ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនស្ទឹមចង្កេះ ដើរទៅក្នុងចន្លោះផ្ទះ ។

២២- ន ខម្ភកតោ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនស្ទឹមចង្កេះ អង្គុយនៅក្នុងចន្លោះផ្ទះ ។

២៣- ន ឱគុណ្ឋិតោ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះ ។

២៤- ន ឱគុណ្ឋិតោ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ។

២៥- ន ឧក្កុដិកាយ អន្តរឃរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនចំអើតជើង ដើរទៅក្នុងចន្លោះផ្ទះ ។

២៦- ន បល្លត្ថិកាយ អន្តរឃរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនត្របោមក្បាលជង្គង់ អង្គុយនៅក្នុងចន្លោះផ្ទះ ។

## ភោជនប្បដិសំយុត្តទី ២ មាន ៣០ គឺៈ

១- សក្កច្ចំ បិណ្ឌបាតប្បដិគ្គហណា សាមណេរ គប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាតដោយគោរព គឺមិនធ្វើអាការដូចជាចាក់ចោល ។

២- បត្តសញ្ញី បិណ្ឌបាតប្បដិគ្គហណា សាមណេរ គប្បីសិក្សាថា អញនឹងសំគាល់តែក្នុងបាត្រ ទទួលបិណ្ឌបាត គឺមិនបានក្រឡេកមើលទៅទីដទៃៗ ។

៣- សមសូបកបិណ្ឌបាតប្បដិគ្គហណា សាមណេរ គប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាតឱ្យមានសម្លស្មើគ្នា ។

៤- សមតិត្តិកបិណ្ឌបាតប្បដិគ្គហណា សាមណេរ គប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាតស្មើតែត្រឹមមាត់បាត្រ ។

៥- សក្កច្ចំ បិណ្ឌបាតភុញ្ជន សាមណេរ គប្បីសិក្សាថា អញនឹងបរិភោគចង្ហាន់បិណ្ឌបាតដោយគោរព គឺមិនធ្វើអាការដូចជា មិនចង់បរិភោគ ។

៦- បត្តសញ្ញី បិណ្ឌបាតភុញ្ជន សាមណេរ គប្បីសិក្សាថា អញនឹងសំគាល់តែក្នុងបាត្រ បរិភោគចង្ហាន់បិណ្ឌបាត គឺមិនបានក្រឡេកមើលទៅទីដទៃៗ ។

៧- សបទានបិណ្ឌបាតភុញ្ជន សាមណេរ

គប្បីសិក្សាថា អញនឹងបរិភោគចង្ហាន់បិណ្ឌបាត វាចឱ្យស្មើ គឺមិនបានកកាយរូងខូងកណ្ដាល ។

៨- សមសូបកបិណ្ឌបាតំ ភុញ្ជន សាមណេរ គប្បីសិក្សាថា អញនឹងបរិភោគចង្ហាន់បិណ្ឌបាតមានសម្លស្មើគ្នា ។

៩- ន ថូបិកតោ ឱមទ្ទិត្វា បិណ្ឌបាតំ ភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបានច្រមចុះអំពីកំពូលបាយ ហើយបរិភោគនូវចង្ហាន់បិណ្ឌបាត ។

១០- ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេន សាមណេរគប្បីសិក្សាថា អញនឹងមិនកកាយបាយលុបសម្ល ឬ ម្ហូបក្រៀម ដើម្បីនឹងឱ្យទាយកគេឱ្យច្រើន ។

១១- ន សូបំ វា ព្យញ្ជនំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជន សាមណេរ គប្បីសិក្សាថា អញមិនមានជំងឺ នឹងមិនសុំសម្ល ឬម្ហូបក្រៀម ឬ បាយ ដើម្បីខ្លួនហើយបរិភោគ ។

១២- ន ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេន សាមណេរ គប្បីសិក្សាថា អញនឹងមិនសំគាល់គិតលើកទោស សម្លឹងមើលបាត្រ សាមណេរដទៃ ។

១៣- នាតិមហន្តំ កពឡំ ករណា សាមណេរគប្បីសិក្សា

Websites: WatKhemaraRatanaram.org or WatKhmers.org

ថា អញនឹងមិនធ្វើពំនូតបាយឱ្យធំហួសប្រមាណ ។

១៤- ន ការវឡាវច្ឆេទកកុញ្ជាន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគខាំកាត់ពំនូតបាយមួយកំណាត់ម្តង ។

១៥- បរិមណ្ឌាលអាលោបការណា សាមណេរគប្បីសិក្សាថា អញនឹងធ្វើអំនូតបាយឱ្យជាបរិមណ្ឌល គឺឱ្យមូល ។

១៦- ន អនាហាតេ ការឡេ មុខទ្វារាវិវរណា សាមណេរគប្បីសិក្សាថា អញកាលបើពំនូតបាយ មិនទាន់ដល់មាត់ នឹងមិនហាមាត់ចាំ ។

១៧- ន កុញ្ជមានោ សព្ពំ ហត្ថំ មុខេ បក្ខិបន សាមណេរគប្បីសិក្សាថា អញកាលបរិភោគនឹងមិនញាត់ម្រាមដៃទាំងអស់ក្នុងមាត់ ។

១៨- ន សកាវឡេន មុខេនព្យាហារណា សាមណេរគប្បីសិក្សាថា អញនឹងមិននិយាយទាំងភោជនក្នុងមាត់ ។

១៩- ន បិណ្ឌុក្ខេបកកុញ្ជាន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគបោះដុំបាយ ដុំត្រី ដុំសាច់ជាដើម ចូលក្នុងមាត់ ។

២០- ន អវគណ្ឌការកកុញ្ជាន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគ បៀមពំនូតបាយឱ្យទុលថ្ពាល់ឡើងដូចជាស្វា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

២១- ន ហត្ថនិទ្ធុនកកុច្ចន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគរលាស់ដៃបណ្ដើរ ។

២២- ន សិត្ថាវការកកុច្ចន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគបាយ ឱ្យរោយរាយគ្រាប់បាយ ។

២៣- ន ជិវ្ហានិច្ឆារកកុច្ចន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគឱ្យឮផ្លុប់ ៗ ។

២៤- ន ចបុចបុការកកុច្ចន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគឱ្យឮផ្លុប់ៗ ។

២៥- ន សុរុសុរុការកកុច្ចន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគហុតទឹកសម្លជាដើម ឱ្យឮគ្រូកៗ ។

២៦- ន ហត្ថនិល្លេហកកុច្ចន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលិទ្ធដៃ ។

២៧- ន បត្តនិល្លេហកកុច្ចន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលិទ្ធបាត្រ ។

២៨- ន ឱដ្ឋនិល្លេហកកុច្ចន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលិទ្ធបបូរមាត់ ។

២៩- ន សាមិសេន ហត្ថេន បានីយថាលកប្បដិគ្គ-ហេតព្វំ សាមណេរគប្បីសិក្សាថា អញនឹងមិនទទួលភាជន៍ទឹក

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយដៃប្រឡាក់អាមិស ។

៣០- ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេន

សាមណេរគប្បីសិក្សាថា អញនឹងមិនចាក់ទឹក ដែលលាងបាត្រ ក្នុងចន្លោះផ្ទះទាំងគ្រាប់បាយ ។

**ធម្មទេសនាបដិសំយុត្តទី ៣ មាន ១៦ គឺ:**

១- ន ឆត្តបាណិស្ស អគិលានស្ស ធម្មំទេសេន

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺ មានឆត្រក្នុងដៃ ។

២- ន ទណ្ឌបាណិស្ស អគិលានស្ស ធម្មំទេសេន

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺ មានឈើច្រត់ក្នុងដៃ ។

៣- ន សត្ថបាណិស្ស អគិលានស្ស ធម្មំទេសេន

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺ មានគ្រឿងសស្ត្រាក្នុងដៃ ។

៤- ន អាវុធបាណិស្ស អគិលានស្ស ធម្មំទេសេន

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺ មានអាវុធក្នុងដៃ ។

៥- ន បាទុការូឡ្ហស្ស អគិលានស្ស ធម្មំទេសេន

Websites: WatKhemaraRatanaram.org or WatKhmers.org

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺ ពាក់ទ្រនាប់ជើងឈើ ឬទ្រនាប់ជើងស្មៅជាដើម ។

៦- ន ឧទាហនារូឡ្ហស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺ ពាក់ស្បែកជើង ។

៧- ន យានគតស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺ នៅលើយាន មានរថជាដើម ។

៨- ន សយនគតស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺ នៅលើទីដំណេក ។

៩- ន បល្លត្ថិកាយ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជំងឺ ត្របោមក្បាលជង្គង់ ។

១០- ន វេឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺ ជួតឈ្នួតក្បាល ។

១១- ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ

Websites: WatKhemaraRatanaram.org or WatKhmers.org

សាមណេរគប្បីសិក្សាថា អញនឹងមិនសំដែងធម៌ ដល់មនុស្សគ្មានជំងឺទទូរក្បាល ។

១២- ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំទេសេន សាមណេរគប្បីសិក្សាថា អញនឹងមិនអង្គុយលើផែនដី សំដែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈ មានកន្ទេលជាដើម ។

១៣- ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មំទេសេន សាមណេរគប្បីសិក្សាថា អញនឹងមិនអង្គុយលើអាសនៈទាប សំដែងធម៌ ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈខ្ពស់ ។

១៤- ន ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំទេសេន សាមណេរគប្បីសិក្សាថា អញនឹងមិនឈរសំដែងធម៌ ដល់មនុស្សគ្មានជំងឺដែលអង្គុយ ។

១៥- ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំទេសេន សាមណេរគប្បីសិក្សាថា អញនឹងមិនដើរអំពីខាងក្រោយ សំដែងធម៌ដល់មនុស្សគ្មានជំងឺ ដើរពីខាងមុខ ។

១៦- ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំទេសេន សាមណេរគប្បីសិក្សាថា អញនឹងមិនដើរក្រៅផ្លូវ សំដែងធម៌ដល់មនុស្សគ្មានជំងឺ ដើរក្នុងផ្លូវ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**បកិណ្ណកទី ៤ មាន ៣ គឺៈ**

១- ន ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករណោ សាមណេរគប្បីសិក្សាថា អញគ្មានជំងឺនឹងមិនឈរបន្ទោឧច្ចារៈឬបស្សាវៈ ។

២- ន ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណោ សាមណេរគប្បីសិក្សាថា អញគ្មានជំងឺនឹងមិនបន្ទោឧច្ចារៈ បស្សាវៈ ឬ ស្តោះទឹកមាត់ដាក់លើភូតគាម គឺដើមឈើឬគុម្ពស្មៅ ។

៣- ន ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណោ សាមណេរគប្បីសិក្សាថា អញគ្មានជំងឺនឹងមិនបន្ទោឧច្ចារៈ បស្សាវៈ ឬ ស្តោះទឹកមាត់ដាក់លើទឹក ដែលមិនគួរនឹងធ្វើដូច្នោះបាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# លោកវជ្ជសិក្ខាបទ
# មាន ៤៩ សិក្ខាបទ

**១- សុក្កវិសដ្ឋិ** សាមណេរក្លែងធ្វើឱ្យទឹកអសុចិកំរើកឃ្លាតចាកទី ត្រូវទណ្ឌកម្ម ។

**២- កាយសំសគ្គ:** សាមណេរមានតម្រេក ចាប់ពាល់ត្រូវកាយស្ត្រី ត្រូវទណ្ឌកម្ម ។

៣- ទុដ្ឋុល្លវាចា សាមណេរមានតម្រេក និយាយពាក្យអាក្រក់ ចែចង់ស្ត្រី ត្រូវទណ្ឌកម្ម ។

**៤- អត្តកាមចារិចរិយា** សាមណេរមានតម្រេក និយាយល្បួងលួងលោមស្ត្រី ឱ្យបម្រើខ្លួនដោយកាម ត្រូវទណ្ឌកម្ម ។

**៥- អមូលក:** សាមណេរក្រោធខឹងនឹងភិក្ខុដទៃ ហើយក្លែងចោទដោយអាបត្តិបារាជិក ដោយមិនមានមូល ត្រូវទណ្ឌកម្ម ។

**៦- អញ្ញភាគិយ:** សាមណេរក្រោធខឹងនឹងភិក្ខុដទៃហើយក្លែងរកលេស មានជាតិជាដើម មកចោទដោយអាបត្តិបារាជិក ត្រូវទណ្ឌកម្ម ។

**៧- សង្ឃភេទ:** សាមណេរព្យាយាមបំបែកសង្ឃ ឱ្យបែកគ្នាភិក្ខុឯទៀតហាមឃាត់មិនស្តាប់ ត្រូវទណ្ឌកម្ម ។

**៨- ភេទានុវត្តក:** សាមណេរប្រព្រឹត្តតាម សាមណេរដែល

Websites: WatKhemaraRatanaram.org or WatKhmers.org

បំបែកសង្ឃនោះ ភិក្ខុឯទៀតហាមឃាត់មិនស្តាប់ ត្រូវទណ្ឌកម្ម ។

៩- **ទុព្ពចជាតិកៈ** សាមណេរមានជាតិ ជាអ្នកបរបឹងរឹងរូស ប្រដៅក្រ ភិក្ខុឯទៀតហាមឃាត់មិនស្តាប់ ត្រូវទណ្ឌកម្ម ។

១០- **កុលទូសកៈ** សាមណេរទ្រុស្តត្រកូលគឺសាមណេរ ដែលប្រចុបប្រចែង ផ្គាប់គុណគ្រហស្ថ សង្ឃបានបណ្តេញចេញ អំពីវត្ត ត្រូវទណ្ឌកម្ម ។

១១- **ចីវរាច្ឆិន្នកៈ** សាមណេរបានឱ្យចីវរដល់សាមណេរ ឯទៀត ហើយដល់ក្រោយខឹងក៏ទៅដណ្តើមយកវិញ ដោយខ្លួនឯងក្តី ប្រើគេឱ្យទៅដណ្តើមយកវិញក្តី បានមក ត្រូវទណ្ឌកម្ម ។

១២- **បរិណាតៈ** សាមណេរដឹងថា លាភដែលទាយកគេ បំរុងនឹងប្រគេនដល់សង្ឃ ហើយបង្អោនសង្ឃលាភនោះ មក ដើម្បីខ្លួនវិញ ត្រូវទណ្ឌកម្ម ។

១៣- **មុសាវាទៈ** សាមណេរពោលពាក្យកុហក ត្រូវ នាសនង្គៈ ។

១៤- **ឱមសវាទៈ** សាមណេរជេរប្រទេស ឬ ពោលពាក្យ ចាក់ដោតសាមណេរផងគ្នា ត្រូវទណ្ឌកម្ម ។

១៥- **បេសុញ្ញៈ** សាមណេរនិយាយញុះញង់សាមណេរផងគ្នា ត្រូវទណ្ឌកម្ម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**១៦- ទុដ្ឋុល្លាវាចនៈ** សាមណេរប្រាប់អាបត្តិអាក្រក់ (គឺអាបត្តិសង្ឃាទិសេស) របស់ភិក្ខុដទៃ ដល់សាមណេរផងគ្នា ត្រូវទណ្ឌកម្ម ។

**១៧- អញ្ញវាទកៈ** សាមណេរប្រព្រឹត្តអនាចារ សង្ឃបានហៅខ្លួនមកសាកសួរ ក្លែងនិយាយត្រឡប់ត្រឡិនក្តី ស្ងៀមមិននិយាយក្តី បើសង្ឃបានសូត្រប្រកាសសេចក្តីនោះចប់ នៅតែធ្វើដូច្នេះទៀត ត្រូវទណ្ឌកម្ម ។

**១៨- ឧជ្ឈាបនកៈ** សាមណេរពោលតិះដៀល ភិក្ខុឯទៀតដែលសង្ឃសម្មតិឱ្យជាអ្នកធ្វើការសង្ឃ មានក្រាលអាសនៈ និងចែកលាភជាដើម បើភិក្ខុនោះធ្វើការសង្ឃដោយប្រពៃ សាមណេរអ្នកតិះដៀលនោះ ត្រូវទណ្ឌកម្ម ។

**១៩- អនុបខជ្ជៈ** សាមណេរដឹងថា កុដិជារបស់សង្ឃមានភិក្ខុចូលទៅនៅមុនហើយ ក្លែងយកសំពត់ទៅក្រាលដេកហើយបានអង្គុយ ឬ ដេកជ្រៀតបៀតក្នុងទីនោះ ដើម្បីនឹងឱ្យភិក្ខុដែលនៅមុននោះ មានសេក្តីចង្អៀតចង្អល់ទុញទាល់ចិត្ត ហើយនឹងចៀសចេញទៅ ត្រូវទណ្ឌកម្ម ។

**២០- និក្កឌ្ឍនៈ** សាមណេរក្រោធខឹងនឹងភិក្ខុឯទៀត ហើយទៅចាប់អូសភើចកន្ត្រាក់ ដេញភិក្ខុនោះឱ្យចេញចាកកុដិជារបស់

Websites: WatKhemaraRatanaram.org or WatKhmers.org

សង្ឃ ត្រូវទណ្ឌកម្ម ។

២១- អាមិសៈ សាមណេរពោលតិះដៀល ភិក្ខុឯទៀតថា ប្រដៅភិក្ខុនី ព្រោះអាស្រ័យលាភសក្ការៈ ត្រូវទណ្ឌកម្ម ។

**២២- ទុតិយប្បវារណា** សាមណេរដឹងថា ភិក្ខុ ឬ សាម-ណេរឯទៀត ហាមភោជនដូច្នោះហើយ គិតនឹងលើកទោសភិក្ខុ ឬ សាមណេរនោះ ៗ ហើយក្លែងយកខាទនីយភោជនីយាហារ ដែលមិនមែនជាភិក្ខុឈឺ ឬ មិនបានធ្វើវិន័យម្ម ទៅអង្វរ ឬ បង្ខំភិក្ខុសាមណេរនោះ ៗ ឱ្យឆាន់ ត្រូវទណ្ឌកម្ម ។

**២៣- ឧយ្យោជនៈ** សាមណេរបបួលភិក្ខុ ឬ សាមណេរឯទៀតទៅបិណ្ឌបាតជាមួយគ្នា គិតនឹងប្រព្រឹត្តអនាចារ ហើយបណ្ដេញភិក្ខុ ឬ សាមណេរនោះ ឱ្យត្រឡប់មកវិញ ត្រូវទណ្ឌកម្ម ។

**២៤- បឋមរហោនិសជ្ជៈ** សាមណេរអង្គុយ ឬ ដេកក្នុងទីកំបាំងភ្នែក តែពីរនាក់នឹងស្ត្រី មិនមានមនុស្សប្រុសនៅជាមួយផង ត្រូវទណ្ឌកម្ម ។

**២៥- ទុតិយរហោនិសជ្ជៈ** សាមណេរអង្គុយ ឬ ដេកក្នុងទីកំបាំងត្រចៀកពីរនាក់នឹងស្ត្រី ត្រូវទណ្ឌកម្ម ។

២៦- ឧយ្យុត្តៈ សាមណេរទៅមើលកងទ័ព ដែលគេលើកទៅដើម្បីច្បាំងគ្នា ត្រូវទណ្ឌកម្ម វៀរលែងតែមានហេតុ គឺមាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ញាតិឈើនៅក្នុងទីនោះ ។

**២៧- សុរាបាន:** សាមណេរផឹកសុរា ត្រូវនាសនង្គៈ ។

២៨- អង្គុលិបតោទក: សាមណេរយកម្រាមដៃចាក់ភិក្ខុ ឬ សាមណេរផងគ្នា ត្រូវទណ្ឌកម្ម ។

**២៩- ហាសធម្ម:** សាមណេរហែលទឹកលេង ត្រូវទណ្ឌកម្ម។

**៣០- អនាទរិយ:** សាមណេរសំដែងសេចក្តីមិនអើពើនឹងវិន័យ ឬនឹងបុគ្គលអ្នកសំដែងវិន័យ ត្រូវទណ្ឌកម្ម ។

**៣១- ភិសាបន:** សាមណេរពញ្ញាក់ ឬ លងបន្លាចភិក្ខុ ឬ សាមណេរផងគ្នា ត្រូវទណ្ឌកម្ម ។

**៣២- អបនិធាន:** សាមណេរលាក់បរិក្ខារ ៥ យ៉ាង គឺ បាត្រ ១, ចីវរ ១, បំពង់ម្ជុល ១, វត្ថពន្ធចង្កេះ ១, និសីទន: ១, បរិក្ខារណាមួយ ជារបស់ភិក្ខុ ឬ សាមណេរឯទៀត ដោយមានបំណងនឹងសើចលេង ត្រូវទណ្ឌកម្ម ។

**៣៣- សញ្ចិច្ចឃាណា:** សាមណេរក្លែងសម្លាប់សត្វតិរច្ឆានត្រូវនាសនង្គៈ ។

៣៤- សប្បាណកា: សាមណេរដឹងថា ទឹកមានសត្វរស់ ហើយបរិភោគនូវទឹកនោះ គឺ ផឹក ងូត លាងងដេ - ជើង ឬ លាង ភាជន៍ជាដើម ត្រូវទណ្ឌកម្ម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**៣៥- ឧក្កោដនៈ** សាមណេរដឹងថា អធិករណ៍ណាមួយ ដែលសង្ឃបានរម្ងាប់ ដោយសមថៈ ៧ យ៉ាង ឯណាមួយ ដោយត្រឹមត្រូវតាមធម៌ស្រេចហើយ មកសើរើសេចក្ដីនោះជាថ្មីទៀត ត្រូវទណ្ឌកម្ម ។

**៣៦- ទុដ្ឋុល្លប្បដិច្ឆាទនៈ** សាមណេរដឹងថា ភិក្ខុឯទៀត ត្រូវទុដ្ឋុល្លាបត្តិ គឺអាបត្តិសង្ឃាទិសេស ហើយជួយបិទបាំងអាបត្តិនោះ ត្រូវទណ្ឌកម្ម ។

**៣៧- អរិដ្ឋៈ** សាមណេរប្រកាន់ទិដ្ឋិបាប គឺមានសេចក្ដីឃើញ ខុសចាកធម៌វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយ ភិក្ខុឯទៀត ពោលហាមប្រាមមិនស្ដាប់ កាលបើសង្ឃបានសូត្រសមនុភាសនកម្មចប់អនុស្សាវនា ជាគម្រប់បីដងហើយ នៅតែមិនស្ដាប់ ត្រូវទណ្ឌកម្ម ។

**៣៨- កណ្ដកៈ** សាមណេរដឹងថា សាមណេរឯទៀតដែលភិក្ខុដទៃ ឱ្យវិនាសហើយ ព្រោះទោសដែលឃើញខុសចាកធម៌វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែង ហើយប្រលោមសាមណេរនោះមក ឱ្យបម្រើខ្លួនក្ដី រួមបរិភោគក្ដី ឱ្យដេកនៅក្នុងទីប្រក់ទីបាំង ជាមួយគ្នាក្ដី ត្រូវទណ្ឌកម្ម ។

**៣៩- សហធម្មិកៈ** សាមណេរប្រព្រឹត្តអនាចារ កាលបើ

Websites: WatKhemaraRatanaram.org or WatKhmers.org

ភិក្ខុដទៃនិយាយដាស់តឿន ក៏និយាយប្រកែកប្រណាំងថា ខ្ញុំព្រះ-ករុណា មិនទាន់សិក្សាសិក្ខាបទនេះទេ ចាំខ្ញុំព្រះករុណា សួរលោកអ្នកឈ្លាស អ្នកចេះដឹង អ្នកទ្រទ្រង់វិន័យសិន ពោលពាក្យដូច្នេះ ត្រូវទណ្ឌកម្ម ។

៤០- **វិលេខនៈ** កាលបើភិក្ខុ ឬ សាមណេរឯទៀត កំពុងទន្ទេញវិន័យ សាមណេរក្លែងនិយាយបន្ទច់បន្ទាក់ ឱ្យគេកើតសេចក្ដីរាយមាយរសាយចាកសេចក្ដីព្យាយាមនោះ ត្រូវទណ្ឌកម្ម ។

៤១- **មោហនៈ** សាមណេរត្រូវទោសទណ្ឌកម្ម ហើយក្លែងនិយាយថា ខ្ញុំព្រះករុណាទើបនឹងដឹង ក្នុងកាលអម្បាញ់មិញនេះឯងថា សេចក្ដីនេះមានក្នុងវិន័យ បើភិក្ខុ ឬ សាមណេរដទៃដឹងថា សាមណេរនោះធ្លាប់ដឹងមកហើយ ដែលពោលដូច្នោះនោះ គឺពោលដោយក្លែងពើធ្វើជាមិនដឹងទៅទេ សង្ឃគប្បីសូត្រប្រកាសមោហារោបនកម្ម កាលបើសូត្រចប់ហើយ នៅតែក្លែងធ្វើជាមិនដឹង ដូច្នោះទៀត ត្រូវទណ្ឌកម្ម ។

៤២- **បហារទានៈ** សាមណេរក្រោធខឹងនឹងភិក្ខុ ឬ សាមណេរឯទៀត ហើយប្រហារភិក្ខុ ឬ សាមណេរនោះ ដោយបហារទាន មានទះតប់ ដាល់ ទាត់ ធាក់ ជាដើម ត្រូវទណ្ឌកម្ម ។

៤៣- **តលសត្តិកៈ** សាមណេរក្រោធខឹងនឹងភិក្ខុ ឬ សាម-

Websites: WatKhemaraRatanaram.org or WatKhmers.org

ណេរឯទៀត ហើយងារដៃឡើងជន្ល ដូចជាប្រហារនូវភិក្ខុ ឬ សាមណេរនោះ ត្រូវទណ្ឌកម្ម ។

**៤៤- អម្វលកៈ** សាមណេរចោទភិក្ខុឯទៀតដោយអាបត្តិសង្ឃាទិសេស ដោយមិនមានមូល គឺថាមិនបានរង្កៀសសោះ ត្រូវទណ្ឌកម្ម ។

**៤៥- សញ្ចិច្ចៈ** សាមណេរក្លែងបង្កហេតុឱ្យសេចក្តីរង្កៀសសង្ស័យព្រួយចិត្ត កើតឡើងដល់ភិក្ខុ ឬ សាមណេរឯទៀត សូម្បីមួយស្របក់ ត្រូវទណ្ឌកម្ម ។

**៤៦- ឧបស្សុតិ** កាលបើភិក្ខុ ឬ សាមណេរ កំពុងវិវាទទាស់ទែងគ្នា សាមណេរទៅលបចាំស្តាប់ដោយគិតថា ភិក្ខុ ឬ សាមណេរនោះពោលពាក្យណា អញនឹងស្តាប់ពាក្យនោះ ហើយប្រាថ្នាចោទលើកទោសផង ត្រូវទណ្ឌកម្ម ។

**៤៧- កម្មប្បដិពាហនៈ** សាមណេរបានឱ្យឆន្ទៈ គឺសេចក្តីប្រាថ្នាព្រមថា ឱ្យសង្ឃកម្មប្រកបដោយធម៌ ហើយមកខាងក្រោយត្រឡប់ពោលតិះដៀលសង្ឃ ដែលធ្វើសង្ឃកម្មនោះវិញ ត្រូវទណ្ឌកម្ម ។

**៤៨- ឆន្ទំ អទត្វា គមនៈ** កាលបើសង្ឃកំពុងប្រជុំគ្នារម្ងាប់អធិករណ៍ ឬ ក៏ពោលទូន្មានវិន័យត្រង់ខណៈណាមួយ សង្ឃធ្វើការនេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

នៅមិនទាន់ហើយស្រេច សាមណេរមិនឱ្យឆន្ទៈ ហើយចៀសចេញទៅ ត្រូវទណ្ឌកម្ម ។

**៤៩- បរិណាមនៈ** សាមណេរដឹងថា លាភដែលទាយកគេបំរុងនឹងប្រគេនដល់សង្ឃ ហើយបង្អោនលាភនោះ មកដើម្បីបុគ្គលវិញ ត្រូវទណ្ឌកម្ម ។

( ដកពីលោកវជ្ជសិក្ខាបទ )

Websites: WatKhemaraRatanaram.org or WatKhmers.org

# វិនយប្បញ្ញត្តិ

ច្បាប់ជាពុទ្ធប្បវេណី ដែលតាំងទុកដើម្បីរៀបចំគ្រប់គ្រងភិក្ខុសាមណេរ ឱ្យមានសណ្ដាប់ធ្នាប់ល្អ ហៅថាវិន័យ ។ វិន័យនេះ បើប្រែតាមរូបស័ព្ទថា "នាំទៅដោយវិសេស" បើប្រែថាតាមអត្ថថា "ធម៌សម្រាប់ទូន្មាននូវកាយនិងវាចា" វិគ្គហៈថា **កាយវាចាយោ វិនេតិ ធមេតីតិ វិនយោ (ធម្មោ)** ។ ឬប្រែថា "ធម៌សម្រាប់ទូន្មាន" វិគ្គហៈថា **វិនេតិ តេនាតិ វិនយោ (ធម្មោ)** ។

កុលបុត្រ ចាកចេញពីត្រកូលផ្សេងៗ ចូលមកសុំបព្វជ្ជាជាសាមណេរ នឹងឧបសម្បទាជាភិក្ខុ ក្នុងព្រះពុទ្ធសាសនានេះ សុទ្ធសឹងមានអធ្យាស្រ័យផ្សេងៗគ្នា ។ កាលបើចូលមកកាន់ភេទជាសាមណេរហើយ, ដោយអំណាចវិន័យ, កុលបុត្រទាំងនោះ ក៏បានជាបព្វជិតមានរបៀបបែបបទដូចគ្នា គួរជាទីជ្រះថ្លានៃជនទាំងពួង ។

វិន័យនេះ លោកប្រៀបដូចចេស ឬអម្បោះ សម្រាប់ក្រងផ្កា គឺចេស ឬអម្បោះអាចនឹងរូបរឹតផ្កា ដែលនាយមាលាការក្រងហើយ ពុំឱ្យខ្ចាត់ខ្ចាយចេញពីគ្នា ព្រោះថាវិន័យអាចនឹងរក្សាសង្ឃឱ្យតាំងនៅដោយល្អបាន ។ រួមគោលធម៌ ៣ យ៉ាងគឺៈ បញ្ញត្តិ ១ អនុញ្ញាត ១ អភិសមាចារ ១ ហៅថា **វិន័យ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ប្រយោជន៍វិន័យ ១០ យ៉ាង

ព្រះបរមគ្រូទ្រង់បញ្ញត្តិវិន័យ

ព្រោះទ្រង់យល់ប្រយោជន៍ ១០ យ៉ាងគឺ៖

១- សង្ឃសុដ្ឋុតាយ ដើម្បីសេចក្ដីល្អដល់សង្ឃ

២- សង្ឃផាសុតាយ ដើម្បីការស្រួលដល់សង្ឃ

៣- ទុម្មង្គូនំ ភិក្ខូនំ និគ្គហាយ ដើម្បីញាំញីពួកភិក្ខុ ដែលទ្រុស្តសីល ។

៤- បេសលានំ ភិក្ខូនំ ផាសុវិហារាយ ដើម្បីនៅជាសុខដល់ពួកភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ។

៥- ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន ។

៦- សម្បរាយិកានំ អាសវានំ បដិឃាតាយ ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយ ក្នុងបរលោក ។

៧- អប្បសន្នានំ បសាទាយ ដើម្បីញ៉ាំងពួកជន ដែលមិនទាន់ជ្រះថ្លាឱ្យជ្រះថ្លា ។

៨- បសន្នានំ ភិយ្យោភាវាយ ដើម្បីញ៉ាំងពួកជន ដែលជ្រះថ្លាហើយ ឱ្យរឹតតែជ្រះថ្លាឡើង ។

៩- សទ្ធម្មដ្ឋិតិយា ដើម្បីញ៉ាំងព្រះសទ្ធម្មឱ្យស្ថិតស្ថេរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

១០- វិនយានុគ្គហាយ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ៤ យ៉ាង មានសំវរវិន័យជាដើម ។

## អានិសង្សអ្នកទ្រទ្រង់វិន័យ ៥ យ៉ាង

១- អត្តនោ សីលក្ខន្ធោ សុគុត្តោ ហោតិ សុរក្ខិតោ វិន័យធរភិក្ខុ មានសីលក្ខន្ធរបស់ខ្លួនគ្រប់គ្រងល្អហើយ រក្សាត្រឹមត្រូវហើយ គឺថាមិនបានត្រូវនូវអាបត្តិ តូច - ធំ ។

២- កុក្កុច្ចប្បកតានំ បដិសរណំ ហោតិ វិន័យធរភិក្ខុ នឹងបានជាទីពំនាក់កុលបុត្រទាំងឡាយ ដែលមានសេចក្តីសង្ស័យ ។

៣- វិសារទោ សង្ឃមជ្ឈេ វោហរតិ វិន័យធរភិក្ខុ នឹងក្លៀវក្លានិយាយវិន័យ ក្នុងកណ្តាលជំនុំសង្ឃ ។

៤- បច្ចត្ថិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ វិន័យធរភិក្ខុ អាចនឹងសង្កត់សង្កិនបុគ្គល ដែលជាសត្រូវក្នុងសាសនា ដោយធម៌ គឺពាក្យប្រកបដោយហេតុបាន ។

៥- សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ វិន័យធរភិក្ខុ បានប្រតិបត្តិត្រឹមត្រូវហើយ ដើម្បីញ៉ាំងព្រះសទ្ធម្មឱ្យដំកល់នៅបាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## អសំវរៈ ឬ ហេតុឱ្យកើតទោស ៥ យ៉ាងគឺៈ

១- ទុស្សីល្យៈ ភាពនៃបុគ្គលទ្រុស្តសីល ។

២- អខន្តិ មិនចេះអត់ធន់នឹងពាក្យទូន្មាន ។

៣- អញ្ញាណៈ មិនស្គាល់សេចក្តីបញ្ញត្តិ ។

៤- មុដ្ឋស្សតិ ភ្លេចស្មារតី ។

៥- កោសជ្ជៈ ភាពខ្ជិលច្រអូស ។

## បើនិយាយតាមព្រះសូត្រមាន ៦ យ៉ាងគឺៈ

១- អាលស្យៈ សេចក្តីខ្ជិលច្រអូស ។

២- បមាទៈ សេចក្តីធ្វេសប្រហែស ។

៣- អនុដ្ឋានៈ សេចក្តីទ្រមក់ មិនក្រវើនក្រតើន ។

៤- អសញ្ញមៈ មិនសង្រួមឥន្ទ្រីយ៍ ។

៥- និទ្ទា ល្ងោភដេក ។

៦- តន្ទី សេចក្តីប្រថុយប្រថានដោយអាងដល់

## ហេតុ ៦ យ៉ាង គឺៈ

១- អតិសីតំ ត្រជាក់ពេក ។

២- អតិឧណ្ហំ ក្តៅពេក ។

៣- អតិបាតោ ព្រឹកពេក ។

៤- អតិសាយំ ល្ងាចពេក ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៥- អតិច្ឆាតោ ឃ្លានបាយពេក ។

៦- អតិបិបាសិតោ ស្រេកទឹកពេក ។

## អន្តរាយឆាមណេរ ៣ យ៉ាងគឺ:

១- កេសច្ឆេទនំ កោរសក់ ។

២- កាសាយអច្ឆាទនំ ស្លៀកសំពត់កាសាយៈ ។

៣- សរណាទានំ ឱ្យត្រៃសរណគមន៍ ។

## កុលបុត្រ ៣២ ជំពូក

ព្រះពុទ្ធទ្រង់ហាមកុលបុត្រ ៣២ ជំពូក មិនឱ្យបព្វជ្ជា គឺ:

១- ហត្ថច្ឆិន្ន មនុស្សកំបុតដៃ ។

២- បាទច្ឆិន្ន មនុស្សកំបុតជើង ។

៣- ហត្ថបាទច្ឆិន្នៈ មនុស្សកំបុតទាំងដៃទាំងជើង ។

៤- កណ្ណច្ឆិន្នៈ មនុស្សកំបុតត្រចៀក ។

៥- នាសច្ឆិន្នៈ មនុស្សកំបុតច្រមុះ ។

៦- កណ្ណនាសច្ឆិន្នៈ មនុស្សកំបុតទាំងត្រចៀកទាំងច្រមុះ។

៧- អង្គុលិច្ឆិន្នៈ មនុស្សកំបុតម្រាមដៃ ។

៨- អឡច្ឆិន្នៈ មនុស្សកំបុតមេដៃមេជើង ។

៩- កណ្ឌរច្ឆិន្នៈ មនុស្សដាច់សរសៃធំ ។

| | |
|---|---|
| ១០- ជាលហត្ថកៈ | មនុស្សមានស្រោមដៃជាប់គ្នា ។ |
| ១១- ខុជ្ជៈ | មនុស្សគម ។ |
| ១២- វាមនៈ | មនុស្សតឿ ។ |
| ១៣- គលគណ្ឌិកៈ | មនុស្សពកក ។ |
| ១៤-លក្ខណាហតៈ | មនុស្សដែលគេបៀតបៀនឱ្យមាន ស្លាកស្នាម។ |
| ១៥- កសាហតៈ | មនុស្សដែលគេវាយដោយរំពាត់ ។ |
| ១៦- លិខិតកៈ | មនុស្សដែលរាជការព្យួរទោសទុក។ |
| ១៧- សីបទី | មនុស្សជើងស្ទក់ ។ |
| ១៨- ចាបរោគី | មនុស្សមានរោគអាក្រក់ ។ |
| ១៩- បរិសទូសកៈ | មនុស្សទ្រុស្តបរិស័ទ ។ |
| ២០- កាណៈ | មនុស្សទើបនឹងខ្វាក់ ។ |
| ២១- កុណី | មនុស្សក្ញេងដៃ-ជើង ។ |
| ២២- ខញ្ជៈ | មនុស្សខ្វក ។ |
| ២៣- បក្ខហតៈ | មនុស្សស្លាប់កាយម្ខាង ។ |
| ២៤- ឆិន្នីរិយាបថៈ | មនុស្សខ្វិន ។ |
| ២៥- ជរាទុព្វលៈ | មនុស្សខ្សោយកំលាំងព្រោះជរា ។ |
| ២៦- អន្ធៈ | មនុស្សខ្វាក់ ។ |

Websites: WatKhemaraRatanaram.org or WatKhmers.org

២៧- មូគះ មនុស្សគ ។

២៨- ពធិរះ មនុស្សថ្លង់ ។

២៩- អន្ធមូគះ មនុស្សទាំងខ្វាក់ទាំងគ ។

៣០- អន្ធពធិរះ មនុស្សទាំងខ្វាក់ទាំងថ្លង់ ។

៣១- មូគពធិរះ មនុស្សទាំងគទាំងថ្លង់ ។

៣២- អន្ធមូគពធិរះ មនុស្សទាំងខ្វាក់-គ ទាំងថ្លង់ ។

កុលបុត្រទាំង ៣២ ជំពូកនេះ បើចចេសបួសទៅ បានឡើងជាសាមណេរដែរ តែអ្នកបំបួសត្រូវអាបត្តិទុក្កដ ។

## សាមណេរ ៥ ពួក

សេពមេថុនធម្ម មិនត្រូវនាសនង្គៈ គឺៈ

១- អជានន្តស្ស អសាទិយន្តស្ស សាមណេរមិនដឹងខ្លួន ទាំងមិនត្រេកអរ ។

២- ឧម្មត្តកស្ស សាមណេរឆ្កួត ។

៣- ខិត្តចិត្តស្ស សាមណេរមានចិត្តរវើរវាយ ។

៤- វេទនដ្ដស្ស សាមណេរដែលវេទនាគ្របសង្កត់។

៥- អាទិកម្មិកស្ស សាមណេរដើមបញ្ញត្តិ ។

( កង្ខាវិតរណី ទំព័រ ៦៦ )

Websites: WatKhemaraRatanaram.org or WatKhmers.org

## ទ្វារមគ្គ ៣០

ឥត្ថី ស្រី ឬ ចាត់តាមកំណើតមាន ៣ ពួកគឺៈ

**១- មនុស្សិត្ថី** ស្រីមនុស្ស ។

**២- អមនុស្សិត្ថី** ស្រីអមនុស្ស ។

**៣- តិរច្ឆានគតិត្ថី** សត្វតិរច្ឆានញី ។

ស្រីទាំង ៣ ពួកនេះ សុទ្ធតែមានទ្វារមគ្គបីៗ ដូចគ្នាគឺៈ

**១- វច្ចមគ្គ** ទ្វារវច្ចៈ គឺទ្វារធំ ។

**២- បស្សាវមគ្គ** ទ្វារបស្សាវៈ គឺទ្វារនោម

**៣- មុខមគ្គ** ទ្វារមាត់ ។ រួមស្រីទាំង ៣ ពួកទៅ ត្រូវជាទ្វារមគ្គ ៩ ។

**ឧភតោព្យញ្ជនក** បុគ្គលមានភេទពីរ ចាត់តាមកំណើតមាន ៣ ពួក, មានទ្វារមគ្គ ៣ ដូចស្រីដែរ ។ រួមទាំង ៣ ពួកត្រូវជាទ្វារមគ្គ ៩ ។

**បុរស** ប្រុស ឬ ឈ្មោល ចាត់តាមកំណើតមាន ៣ ពួក, មានទ្វារមគ្គពីរ គឺ **វច្ចមគ្គ** និង **មុខមគ្គ** ។ រួមទាំង ៣ ពួក ត្រូវជាទ្វារមគ្គ ៦ ។

**បណ្ឌក** ខ្ទើយ ចាត់តាមកំណើតមាន ៣ ពួក មានទ្វារមគ្គពីរ គឺ **វច្ចមគ្គ** និង **មុខមគ្គ** ដូចបុរស។ រួមទាំង ៣ ពួក ត្រូវជាទ្វារមគ្គ ៦ ។

បូករួមទ្វារមគ្គ ៩ + ៩ + ៦ + ៦ = ៣០ ទ្វារមគ្គគត់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## អកប្បិយមំស ១០ យ៉ាង:

ព្រះពុទ្ធបរមគ្រូ ទ្រង់ហាមមិនឱ្យភិក្ខុ - សាមណេរឆាន់

អកប្បិយមំស: សាច់មិនគួរឆាន់ ១០ យ៉ាងគឺ:

១- មនុស្សមំស: សាច់មនុស្ស

២- ហត្ថិមំស: សាច់ដំរី

៣- អស្សមំស: សាច់សេះ

៤- សុនខមំស: សាច់ឆ្កែស្រុក

៥- តរច្ឆមំស: សាច់ឆ្កែព្រៃ

៦- អហិមំស: សាច់ពស់

៧- សីហមំស សាច់សីហ:

៨- ព្យគ្ឃមំស: សាច់ខ្លាធំ

៩- ទីបិមំស: សាច់ខ្លាដំបង

១០- អច្ឆមំស: សាច់ខ្លាឃ្មុំ

## សមណកប្ប: ៥ យ៉ាង:

វត្ថុដែលគួរដល់សមណ: អាចឆាន់បានតាមសប្បាយ មាន ៥ យ៉ាងគឺ:

១- អគ្គិបរិចិតំ វត្ថុដែលបុគ្គលចំអិនដោយកំដៅភ្លើង

២- សត្ថបរិចិតំ វត្ថុដែលបុគ្គលចិតចោះឆ្កឹះដោយកំបិត

៣- នខបរិចិតំ វត្ថុដែលបុគ្គលកេះកោសចុចដោយក្រចក

៤- អតីជំ វត្ថុមិនដុះតទៅទៀត គឺផ្លែឈើខ្ចី

៥- និព្វដតីជំ វត្ថុដែលយកពូជ (គឺគ្រាប់) ចេញបាន ដូច ល្មុតជាដើម ។

(គម្ពីរមហាវគ្គ ភេសជ្ជក្ខន្ធកៈ)

## ពូជ ៥ យ៉ាង

ព្រះសម្មាសម្ពុទ្ធទ្រង់ហាមភិក្ខុសាមណេរមិនឱ្យបៀតបៀនពូជ ៥ យ៉ាងគឺៈ

១- មូលវីជំ ពូជកើតអំពីមើម = ខ្ញី, រំដេង, ដំឡូង...

២- ខន្ធវីជំ ពូជកើតអំពីដើម = ពោធិ៍, ជ្រៃ, លៀប...

៣- ផឡុវីជំ ពូជកើតអំពីថ្នាំង = អំពៅ , ឫស្សី...

៤- អគ្គវីជំ ពូជកើតអំពីគល់ឬចុង = ជីរលីងលាក់,ចេក...

៥- វីជវីជំ ពូជកើតអំពីពូជ = ស្រូវ, ពោត...

(កង្ខាវិតរណី ភូតគាមវគ្គ)

## អាសនៈ ២០ យ៉ាងៈ

អាសនៈខ្ពស់ និង អាសនៈប្រសើរមាន ២០ យ៉ាងគឺៈ

១- អាសន្ទិ អាសនៈខ្ពស់ហួសប្រមាណ ។

២- បល្លង្កៈ គ្រែមានជើងខ្ពស់វិចិត្ររូបសត្វសាហាវ ។

៣- គោណកៈ ព្រំមានរោមវែងជាង ៤ ធ្នាប់ ។

៤- ចិត្តកៈ កម្រាលរោមសត្វសាហាវ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៥- បដិកៈ កម្រាលពណ៌ធ្វើពីរោមសត្វ ។

៦- បដលិកៈ កម្រាលរោមសត្វជាផ្កាចង្កោម ។

៧- តូលិកៈ កម្រាលញាត់សំឡីគរ ។

៨- វិកតិកៈ កម្រាលរោមសត្វវិចិត្ររូបសីហៈ និងខ្លា ។

៩- ឧទ្ទលោមិ កម្រាលរោមសត្វមានរោមច្រាងតែម្ខាង។

១០- ឯកន្តលោមិ កម្រាលរោមសត្វមានរោមច្រាងទាំងពីរខាង។

១១- កដិស្សៈ កម្រាលឱនមាសនិងសូត្រ ស្រែះដោយរតនវត្ថុ ។

១២- កោសេយ្យៈ កម្រាលធ្វើពីសរសៃសូត្រ ស្រែះដោយរតនវត្ថុ ។

១៣- កុត្តកៈ កម្រាលរោមសត្វល្មមស្រីរបាំ ១៦ នាក់ឈររាំបាន ។

១៤- ហត្ថត្ថរៈ កម្រាលសម្រាប់ក្រាលលើខ្នងដំរី ។

១៥- អស្សត្ថរៈ កម្រាលសម្រាប់ក្រាលលើខ្នងសេះ ។

១៦- រថត្ថរៈ កម្រាលសំរាប់ក្រាលលើរថ ។

១៧- អជិនប្បវេណិ កម្រាលធ្វើពីស្បែកខ្លាឃ្មុំ ។

១៨- កទលិមិគបវរបច្ចត្ថរណៈ កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វឈ្លូស ។

Websites: WatKhemaraRatanaram.org or WatKhmers.org

១៩- **សឧត្តរច្ឆទៈ** ទីដេកមានពិតានក្រហមខាងលើ ។

២០- **ឧភតោលោហិតកូបធានំ** កម្រាលដែលមានខ្នើយមានពណ៌ក្រហមទាំងពីរខាង គឺខ្នើយក្បាល និងជើង ។

អាសនៈទាំង ២០ យ៉ាងនេះ លើកតែ អាសន្ទិ ១ បល្លង្ក ១ តូលិក ១ អាសនៈទាំង ៣ នេះ អង្គុយក៏មិនបាន ដេកក៏មិនបាន ក្រៅពីនេះ ១៧ ទៀត ទ្រង់អនុញ្ញាតឱ្យអង្គុយបាន តែដេកមិនបានទេ សាមណេរត្រូវទណ្ឌកម្ម ។

## ពូក ៥ យ៉ាង

ទ្រង់អនុញ្ញាតឱ្យសាមណេរប្រើប្រាស់ពូក ៥ យ៉ាងគឺៈ

១- **ឧណ្ណាភិសិ** ពូកញាត់ដោយរោមកែះ ។

២- **ចោឡភិសិ** ពូកញាតិសំពត់ ។

៣- **វាកភិសិ** ពូកញាត់សំបកឈើ ។

៤- **តិណភិសិ** ពូកញាតិស្មៅ ។

៥- **បណ្ណភិសិ** ពូកញាត់ស្លឹកឈើ ។

## គ្រែ ៤ យ៉ាង

ព្រះអង្គទ្រង់អនុញ្ញាតឱ្យដេក-អង្គុយបានលើគ្រែ ៤ យ៉ាងគឺៈ

១- **មសារកៈ** គ្រែដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង។

២- **ពុន្ទិកាពទ្ធៈ** គ្រែដែលមានមេជាប់នឹងជើង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៣- កុលិរថាទកៈ គ្រែដែលមានជើងដូចជាជើងក្ដាម ។

៤- អាហច្ចថាទកៈ គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ ។

## ទ្រនំអនុញ្ញាតតាំង ៤ យ៉ាងគឺៈ

១- មសារកៈ តាំងដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង ។

២- ពុន្ទិកាពទ្ធៈ តាំងដែលមានមេបង្ខាំជាប់នឹងជើង ។

៣- កុលិរថាទកៈ តាំងដែលមានជើងដូចជាជើងក្ដាម ។

៤- អាហច្ចថាទកៈ តាំងដែលមានជើងចុច ឬតាំងដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ ។

## សុរា ៥ យ៉ាងគឺៈ

១- បិដ្ឋសុរា សុរាធ្វើដោយម្សៅ ។

២- បូវសុរា សុរាធ្វើដោយនំ ។

៣- ឱទនសុរា សុរាធ្វើដោយបាយ ។

៤- កិណ្ណបក្ខិត្តា សុរាដែលគេដាក់ពូជសុរា ។

៥- សម្ភារសំយុត្តា សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ មានគ្រាប់ម្រេច និងគ្រាប់ស្ពៃជាដើម ។

## មេរ័យ ៥ យ៉ាង

១- បុប្ផាសវោ ទឹកត្រាំធ្វើពីផ្កាឈើ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

២- ផលាសវោ ទឹកត្រាំធ្វើពីផ្លែឈើ ។

៣- មធ្វាសវោ ទឹកត្រាំធ្វើពីផ្លែចន្ទន៍ ឬ ទឹកឃ្មុំ ។

៤- គុឡាសវោ ទឹកត្រាំធ្វើពីទឹកអំពៅ ។

៥- សម្ភារសំយុត្តោ ទឹកត្រាំដែលគេប្រកបគ្រឿងផ្សំផ្សេងៗ មានផ្លែសម៉ និង ផ្លែកន្ទួតព្រៃជាដើម ។

## បាត្រ

ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យប្រើបាត្រ ២ បែបគឺៈ

បាត្រដីដុត ១ ។

បាត្រដែក ១ ។

## ទ្រង់ហាមមិនឱ្យប្រើបាត្រ ១១ យ៉ាងគឺៈ

បាត្រមាស ១, បាត្រប្រាក់ ១

បាត្រកែវមណី ១, បាត្រកែវពិទូរ្យ ១

បាត្រកែវផលិក ១, បាត្រកែវកញ្ចក់ ១

បាត្រសំរិទ្ធ ១, បាត្រសំណប៉ាហាំង ១

បាត្រសំណភក់ ១, បាត្រឈើ ១ និង បាត្រស្ពាន់ ១ ។

## ប្រគេនប្រកបដោយអង្គ ៥ យ៉ាង គឺៈ

១- ថាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណាមត្តំ ហោតិ ទេយ្យវត្ថុមានទម្ងន់ល្មមបុរសមានកម្លាំងយ៉ាងកណ្តាលលើករួច ។

Websites: WatKhemaraRatanaram.org or WatKhmers.org

២- ហត្ថបាសោ បញ្ញាយតិ ត្រឹមត្រូវតាមហត្ថបាស គឺ ២ ហត្ថ ១ ចំអាម ។

៣- អភិហារោ បញ្ញាយតិ អ្នកប្រគេនត្រូវបន្ទន់ខ្លួន បង្អោនវត្ថុ ចូលទៅរកបដិគ្គាហកៈ ។

៤- ទេវោ វា មនុស្សោ វា តិរច្ឆានគតោ វា ទេតិ ទេវតាក្តី មនុស្សក្តី តិរច្ឆានក្តី ប្រគេនបព្វជិតអាចទទួលឆាន់បាន ។

៥- តំ ចេ ភិក្ខុ កាយេន វា កាយប្បដិពទ្ធេន វា បដិគ្គណ្ហាតិ បព្វជិតទទួលវត្ថុនោះដោយកាយក៏បាន ដោយវត្ថុជាប់ដោយកាយក៏បាន ។

**អ្នកបួស ៦ យ៉ាងគឺ:**

១- ឧបកីឡិកា បួសពេញចិត្តនឹងការលេង ។

២- ឧបទូសិកា បួសទ្រុស្តសីលប្រទុស្តសាសនា ។

៣- ឧបមុយ្ហិកា បួសល្ងង់ខ្លៅ ។

៤- ឧបជីវិកា បួសគ្រាន់តែចិញ្ចឹមជីវិត ។

៥- អាចិណ្ណសម្បត្តិ បួសសន្សំទ្រព្យ ។

៦- ឧបនិស្សរណា បួសដើម្បីនឹងរលាស់ខ្លួនចាកចេញភព ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# មហាភិនិក្ខមនបរិច្ឆេទ ទី ៦

កាលព្រះសម្ពុទ្ធទ្រង់ចេញបព្វជ្ជានោះ

១- ទ្រង់យក ចិត្ត ជាសីមា

២- ទ្រង់យក បញ្ញា ជាព្រះឧបជ្ឈាយ៍

៣- ទ្រង់យក សច្ចៈ ជាកម្មវាចា

៤- ទ្រង់យក សតិ ជាអនុស្សាវនា

៥- ទ្រង់យក ឋានយវត្ថុ ជាអាចារ្យ

៦- ទ្រង់យក ចេតសិក ជាសង្ឃហត្ថបាស ។

## អវន្ទិយបុគ្គលៈ

បុគ្គលដែលភិក្ខុ-សាមណេរមិនត្រូវសំពះ មិនត្រូវថ្វាយបង្គំ ហៅថា អវន្ទិយបុគ្គល មាន ២៥ ប្រភេទ គឺៈ

១- អន្តរឃរំ បវិដ្ឋោ ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ ។

២- វច្ឆំ គតោ ភិក្ខុកំពុងដើរតាមច្រកល្ហក ។

៣- ឱតមសិកោ ភិក្ខុកំពុងដើរតាមច្រកល្ហក ។

៤- អសមន្នាហារេន្តោ ភិក្ខុកំពុងខ្វល់ខ្វាយក្នុងកិច្ចការអ្វីមួយ

៥- សុត្តោ ភិក្ខុកំពុងសឹងលក់ ។

៦- យាគុបានេ (ភិក្ខុ) កំពុងឆាន់បបរ ។

៧- ខាទន្តោ ភិក្ខុកំពុងឆាន់បង្អែម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៨- ភុញ្ជន្តោ ភិក្ខុកំពុងឆាន់ចំអាប ។

៩- ភត្តគ្គេ ភិក្ខុកំពុងនៅក្នុងរោងភត្ត ។

១០-ឯកាវត្តោ ភិក្ខុជាសត្រូវនឹងគ្នា ។

១១- អញ្ញាវិហិតោ ភិក្ខុកំពុងភាំងគំនិតគិតអ្វីមួយ ។

១២- ឧច្ចារំ ករោន្តោ ភិក្ខុកំពុងបន្ទោឧច្ចារៈ ។

១៣- បស្សាវំ ករោន្តោ ភិក្ខុកំពុងបន្ទោបស្សាវៈ ។

១៤- នគ្គោ ភិក្ខុអាក្រាត ។

១៥- ឧក្ខិត្តកោ ភិក្ខុដែលសង្ឃលើកវត្ត ។

១៦- បច្ឆាឧបសម្បន្នោ ភិក្ខុបានឧបសម្បទាក្រោយ ។

១៧- អនុបសម្បន្នោ អនុបសម្បន្ន ។

១៨- នានាសំវាសកោ វុឌ្ឍតរោ អធម្មវាទី ភិក្ខុនានាសំវាសកៈ ជាអធម្មវាទី ទោះបីចាស់វស្សាជាងក៏ដោយ ។

១៩- មាតុគាមោ មាតុគ្រាម ។

២០- បណ្ឌកោ បណ្ឌកៈ (ខ្ទើយ) ។

២១- ចារិវាសិកោ ភិក្ខុកំពុងចូលបរិវាស ។

២២- មូលាយបដិកស្សនារហោ ភិក្ខុដែលគួរនឹងទាញកាន់ មូលាបត្តិ ។

២៣- មានត្តារហោ ភិក្ខុដែលគួរដល់មានត្ត ។

Websites: WatKhemaraRatanaram.org or WatKhmers.org

២៤- មានត្តចារិកោ ភិក្ខុដែលកំពុងប្រព្រឹត្តមានត្ត ។

២៥- អព្ភានារហោ ភិក្ខុដែលគួរដល់អព្ភានកម្ម ។

អវន្ទីយបុគ្គលពីលេខ ១ ដល់លេខ ១៣ សាមណេរ ពុំគួរសំពះ ពុំគួរថ្វាយបង្គំ បើសំពះឬថ្វាយបង្គំ ក៏ឥតមានទោសទេ តែជាអសារុប្បៈ គឺជាការមិនល្អមើល ចំណែកអវន្ទីយបុគ្គលពីលេខ ១៤ ដល់ ២៥ សាមណេរសំពះ ឬថ្វាយបង្គំត្រូវមានទោស ។

(គម្ពីរបរិវារៈ វិន័យបិដក)

ម្យ៉ាងទៀត ទោះបីភិក្ខុដែលទើបក្រោកពីសឹង ពុំទាន់ខ្ពុរមាត់លុបមុខ ឬកំពុងស្រង់ទឹក ក៏ពុំគួរថ្វាយបង្គំដែរ ឬចំពោះកិច្ចវត្តទី ១៦ សាមណេរ ត្រូវថ្វាយបង្គំបាន តែភិក្ខុដូចគ្នា ថ្វាយបង្គំមិនបាន ។

## វន្ទីយបុគ្គល

បុគ្គលដែលសាមណេរ គួរធ្វើវន្ទនកម្ម ហៅថា
វន្ទីយបុគ្គលមាន ៥ ប្រភេទ គឺៈ

១- បុរេឧបសម្បន្នោ ភិក្ខុដែលបានឧបសម្បទាមុន ។

២- នានាសំវាសកោ វុឌ្ឍតរោ ធម្មវាទី ភិក្ខុនានាសំវាសកៈ ជាធម្មវាទី ដែលមានវស្សាចាស់ផង ។

៣- អាចរិយោ ភិក្ខុជាអាចារ្យ ( របស់ខ្លួន ) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៤- ឧបជ្ឈាយោ ភិក្ខុជាឧបជ្ឈាយ៍ (របស់ខ្លួន) ។

៥- តថាគតោ អរហំ សម្មាសម្ពុទ្ធោ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ។

(វិន័យបិដក បរិវារៈ ភាគ ១៣)

## អាចារ្យ

ភិក្ខុដែលសិស្សត្រូវគោរពដោយអើពើ ហៅថា អាចារ្យមាន ៥ ប្រភេទគឺ

១- បព្វជ្ជាចារ្យ អាចារ្យអ្នកឱ្យបព្វជ្ជា ជាសាមណេរ ។

២- ឧបសម្បទាចារ្យ អាចារ្យសូត្រឧបសម្បទាកម្មជាភិក្ខុ ។

៣- និស្សយាចារ្យ អាចារ្យឱ្យនិស្ស័យ ។

៤- ឧទ្ទេសាចារ្យ ឬ ធម្មាចារ្យ អាចារ្យបង្រៀនបាលី ឬ ធម៌។

៥- ឱវាទាចារ្យ អាចារ្យឱ្យឱវាទ ។

## អន្តេវាសិក

ភិក្ខុ សាមណេរ ជាសិស្សរបស់អាចារ្យទាំង ៥ ប្រភេទនេះ ហៅថា អន្តេវាសិក មាន ៥ ប្រភេទដែរគឺៈ

១- បព្វជ្ជន្តេវាសិកៈ អន្តេវាសិករបស់បព្វជ្ជាចារ្យ ។

២- ឧបសម្បទន្តេវាសិកៈ អន្តេវាសិករបស់ឧបសម្បទាចារ្យ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៣- **និស្សយន្តេវាសិកៈ** អន្តេវាសិករបស់និស្សយាចារ្យ ។

៤- **ឧទ្ទេសន្តេវាសិកៈ** អន្តេវាសិករបស់ឧទ្ទេសាចារ្យ ។

៥- **ឱវាទន្តេវាសិកៈ** អន្តេវាសិករបស់ឱវាទាចារ្យ ។

## វន្ទនកម្ម

សាមណេរ គប្បីធ្វើវន្ទនកម្មជិតបាទាលោកគ្រូ ដោយធម៌ប្រកបដោយអង្គ ៥ យ៉ាងគឺៈ

១- គ្រងចីវរស្នាម្ខាង ។

២- ប្រណម្យអញ្ជលីទាំង ១០ ។

៣- ច្របាច់បាទាលោកដោយដៃទាំងពីរ ។

៤- តាំងសេចក្តីស្រឡាញ់ចំពោះលោក ។

៥- តាំងសេចក្តីគោរពចំពោះលោក ។

(វិន័យបិដក បរិវារៈ ភាគ ១៣)

តាមអង្គវន្ទនកម្មទី១ ឃើញថា ភិក្ខុ-សាមណេរ ដែលឃ្លុំចីវរ ឬដណ្តប់ចីវរស្នាទាំងពីរខាង មិនគួរថ្វាយបង្គំភិក្ខុ ដែលខ្លួនត្រូវធ្វើវន្ទនកម្មទេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## បច្ចវេក្ខណៈ

បច្ចវេក្ខណៈ គឺលក្ខណៈសម្រាប់ពិចារណានូវបច្ច័យ
ដែលខ្លួនត្រូវអាស្រ័យ មាន ៤ គឺៈ

ធាតុប្បច្ចវេក្ខណៈ១ បដិក្កូលប្បច្ចវេក្ខណៈ១
តន្ហ្វណិកប្បច្ចវេក្ខណៈ ១ អតីតប្បច្ចវេក្ខណៈ ១ ។

## ធាតុប្បច្ចវេក្ខណៈ

ធាតុប្បច្ចវេក្ខណៈនេះ គឺឱ្យពិចារណាក្នុងកាលទទួល
បច្ច័យ ៤ ឱ្យឃើញថាជាធាតុ ។
កាលទទួលចីវរប្បច្ច័យ ឱ្យពិចារណា ថាៈ

**យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ**
**យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ**
**ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ**

សំពត់ចីវរឯណានេះ សំពត់ចីវរនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្ត ទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គលគឺអាត្មា ដែលជាអ្នកប្រើប្រាស់ សំពត់ចីវរនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កាលទទួលបិណ្ឌបាតបច្ច័យ ឱ្យពិចារណាថាៈ

**យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ**

ចង្ហាន់បិណ្ឌបាតឯណានេះ ចង្ហាន់បិណ្ឌបាតនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គលគឺអាត្មាដែលជាអ្នកបរិភោគ ចង្ហាន់បិណ្ឌបាតនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលទទួលសេនាសនបច្ច័យ ឱ្យពិចារណាថាៈ

**យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ សេនាសនំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ**

ទីសេនាសនៈឯណានេះ ទីសេនាសនៈនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គលគឺអាត្មា ដែលជាអ្នកបរិភោគប្រើប្រាស់ សេនាសនៈនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលទទួលគិលានបច្ច័យ ឱ្យពិចារណាថាៈ

**យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ**

Websites: WatKhemaraRatanaram.org or WatKhmers.org

យថិទំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យទុកជាបុគ្គលគឺអាត្មា ដែលជាអ្នកបរិភោគ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

## បដិកូលប្បច្ចវេក្ខណៈ

បដិកូលប្បច្ចវេក្ខណៈនេះ គឺឱ្យពិចារណាក្នុងខណៈប្រាវព្ធ និងបរិភោគបច្ច័យ ៤ ឱ្យឃើញថា ជារបស់បដិកូល គួរខ្ពើមឆ្អើម ។

កាលប្រាវព្ធប្រើប្រាស់ចីវរប្បច្ច័យ ឱ្យពិរណាថា:

សព្វានិ បនិមានិ ចីវរានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ

សំពត់ចីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ កាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សព្វោ បនាយំ បិណ្ឌបាតោ អជិគុច្ឆនីយានិ ឥមំ
បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

ចង្ហាន់បិណ្ឌបាតទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ កាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលប្រារព្ធប្រើប្រាស់សេនាសនប្បច្ច័យ ពិចារណាថា:

សព្វានិ បនិមានិ សេនាសនានិ អជិគុច្ឆនីយានិ
ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ

ទីសេនាសនៈ ទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ កាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលប្រារព្ធបរិភោគគិលានប្បច្ច័យ ពិចារណាថា:

សព្វោ បនាយំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ
អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា
អតិវិយ ជិគុច្ឆនីយោ ជាយតិ

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ
ទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់

Websites: WatKhemaraRatanaram.org or WatKhmers.org

កាយស្អុយនេះ កាលណាហើយក៏កើតជា របស់គួរខ្ពើមរអើមក្រៃពេក។

## តង្ខណិកបច្ចវេក្ខណៈ

តង្ខណិកបច្ចវេក្ខណៈនោះ គឺឱ្យពិចារណាក្នុងខណៈ

ដែលបរិភោគនូវបច្ច័យ ៤ ។

កាលប្រើប្រាស់ចីវរបច្ច័យ ពិចារណាថាៈ

បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។

បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរ កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និង ពស់តូច ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឱ្យកំរើក ។

កាលបរិភោគបិណ្ឌបាតបច្ច័យ ពិចារណាថាៈ

បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ

នវិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

បព្វជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូចក្មេងអ្នកស្រុក ក៏ទេ ដើម្បីនឹងឱ្យកើតបុរិសៈមានៈស្រវឹង ដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយ ដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់ សម្បុរដូចអ្នកលេងរបាំងក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឱ្យតាំងនូវនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រីយ៍ ឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់ នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារីយ៍ អញនឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅ នៃឥរិយាបថទាំងបួនក្តី សេចក្តីមិនមានទោស មានមិនច្រអូសកាយ មិនច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំងបួនក្តី នឹងមិនដល់អញ ដោយបានបរិភោគ នូវចង្ហាន់បិណ្ឌបាតនេះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កាលប្រើប្រាស់សេនាសនប្បច្ច័យ ពិចារណាថា:

**បដិសង្ខា យោនិសោ សេនាសនំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។**

បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគប្រើប្រាស់ នូវទីសេនាសនៈ កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និង ពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបន្ទោបង់ នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

កាលបរិភោគគិលានប្បច្ច័យ ពិចារណាថា:

**បដិសង្ខា យោនិសោ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារំ បដិសេវាមិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ**

បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេពគឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

បរិភោគនូវគ្រឿងបរិក្ខារ ជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ កំណត់ទុក ដើម្បីនឹងការពារ នូវវេទនាទាំងឡាយដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។

## អតីតប្បច្ចវេក្ខណៈ

អតីតប្បច្ចវេក្ខណៈនេះ គឺឱ្យពិចារណានូវបច្ច័យ៤ ក្នុងអតីតកាល គឺកាលដែលបរិភោគរួចហើយ ឱ្យបានមួយចប់ ពីរចប់ ឬបីចប់ក៏បាន តែត្រូវពិចារណាបានតែក្នុងថ្ងៃនោះ គឺក្នុងវេលាយប់មួយថ្ងៃមួយ កុំឱ្យអរុណរះឡើងទាន់ ។

កាលដែលនឹងពិចារណានូវចីវរប្បច្ច័យ ឱ្យពិចារណាថា:

**អជ្ជ មយា អប្បច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។**

សំពត់ចីវរឯណា ដែលអញមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះអញប្រើប្រាស់ កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និង ពស់តូច ពស់ធំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទាំងឡាយ កំណត់ទុក ដើម្បីនឹងបិទបាំងនូវអវៈយវៈ ដែលធ្វើនូវសេចក្ដីខ្មាសឱ្យកំរើក ។

កាលដែលនឹងពិចារណានូវបិណ្ឌបាតបច្ច័យ ឱ្យពិចារណាដូច្នេះថា:

អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ។

ចង្ហាន់បិណ្ឌបាតឯណា ដែលអញ មិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ ចង្ហាន់បិណ្ឌបាតនោះ អញបរិភោគ ដើម្បីនឹងលេងដូចក្មេងអ្នកស្រុក ក៏ទេ ដើម្បីនឹងឱ្យកើតបុរិសៈមានៈស្រវឹងដូចអ្នកប្រដាល់ ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងកាយដូចស្ត្រីក្នុងបុរី ក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំ ក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រិយ ឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់ នូវវេទនាចាស់

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្តីឃ្លានដែលមានហើយផង និងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តិទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស មានមិនច្រអូសកាយមិនច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុង ឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ។

កាលដែលនឹងពិចារណានូវសេនាសនបច្ច័យ ឱ្យពិចារណាដូច្នេះថា:

**អជ្ជ មយា អបច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។**

ទីសេនាសនៈឯណា ដែលអញ មិនបានពិចារណាហើយ បរិភោគប្រើប្រាស់ហើយ ក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូល ខ្យល់ កំដៅថ្ងៃ និង ពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កាលដែលពិចារណានូវគិលានបច្ច័យ ឱ្យពិចារណាដូច្នេះថា៖

**អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ គិលានប្បច្ចយភេ-សជ្ជបរិក្ខារោ បរិភុត្តោ សោ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យា-បជ្ឈបរមតាយាតិ ។**

គ្រឿងបរិក្ខារ ជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ អញបរិភោគ កំណត់ទុក ដើម្បីនឹងការពារនូវវេទនាទាំង-ឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។

បើនៅពេលទទួល ពេលប្រារព្ធដើម្បីនឹងបរិភោគ និងពេលបរិភោគបានពិចារណាដោយធាតុប្បច្ចវេក្ខណៈ បដិកូលប្បច្ចវេក្ខណៈ តង្ខណិ-កប្បច្ចវេក្ខណៈ រួចសព្វគ្រប់ហើយ នឹងមិនបាច់ពិចារណាក្នុងអតីតប្បច្ច-វេក្ខណៈទៀតក៏បាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## បច្ច័យ ៤

វត្ថុដែលបព្វជិតត្រូវអាស្រ័យ បរិភោគប្រើប្រាស់ហើយទើបប្រព្រឹត្តទៅបាន ហៅថា បច្ច័យៗ នោះមាន ៤ យ៉ាងគឺៈ

១- ចីវរប្បច្ច័យ បច្ច័យគឺគ្រឿងស្លៀកដណ្តប់ ។

២- បិណ្ឌបាតប្បច្ច័យ បច្ច័យ គឺចង្ហាន់បិណ្ឌបាត ។

៣- សេនាសនប្បច្ច័យ បច្ច័យ គឺសេនាសនៈ ។

៤- គិលានភេសជ្ជប្បច្ច័យ បច្ច័យ គឺថ្នាំសម្រាប់ព្យាបាលអ្នកជំងឺ ។

## បច្ចវេក្ខណៈ ៤

លក្ខណៈសម្រាប់ពិចារណានូវបច្ច័យទាំង ៤ នោះ ហៅថា បច្ចវេក្ខណៈ ៗ នោះមាន ៤ យ៉ាងគឺៈ

១- ធាតុប្បច្ចវេក្ខណៈ ពិចារណានូវបច្ច័យថា គ្រាន់តែជាធាតុ ។

២- បដិក្កូលប្បច្ចវេក្ខណៈ ពិចារណានូវបច្ច័យថាជារបស់បដិកូល ។

៣- តំខណិកប្បច្ចវេក្ខណៈ ពិចាណារនូវបច្ច័យក្នុងខណៈកំពុងប្រើប្រាស់ បរិភោគនោះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៤- អតីតប្បច្ចវេក្ខណៈ ពិចារណានូវបច្ច័យដែលបានបរិភោគកន្លងទៅហើយ ។

បច្ច័យមួយៗ មានបច្ចវេក្ខណៈបួនៗ រួមត្រូវជាបច្ចវេក្ខណៈ ១៦ ។

## បច្ចវេក្ខណកាល ៣

កាលដែលត្រូវពិចារណានូវបច្ច័យនោះ ៗ ហៅថា

បច្ចវេក្ខណកាលមាន ៣ យ៉ាងគឺៈ

១- បដិលាភកាល កាលដែលកំពុងបាន-កំពុងទទួល ។

២- បរិភោគកាល កាលដែលកំពុងបរិភោគ ។

៣- អតីតកាល កាលដែលបានបរិភោគកន្លងហើយ។

## ដែនរបស់ប្រយោជន៍ ក្នុងបច្ច័យទាំង ៤
## ចីវរប្បច្ច័យ

មានកំណត់ដែនរបស់ប្រយោជន៍ ៤ យ៉ាងគឺៈ

១- សីតស្ស បដិឃាតាយ ដើម្បីការពារនូវត្រជាក់ ។

២- ឧណ្ហស្ស បដិឃាតាយ ដើម្បីការពារនូវកំដៅ ។

៣- ដំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ ដើម្បីការពារនូវសម្ផស្ស របោម មូល ខ្យល់ កំដៅថ្ងៃ ពស់តូច និង ពស់ធំទាំងឡាយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៤- ហិរិកោបិនប្បដិច្ឆាទនត្ថំ ដើម្បីបិទបាំងអវយវៈដែលធ្វើនូវសេចក្តីខ្មាសឱ្យកម្រើក ។

## បិណ្ឌបាតបច្ច័យ

ចាត់ជាអង្គត្រូវឃាត់ ៤ យ៉ាងគឺៈ

១- នេវ ទវាយ មិនមែនដើម្បីល្បែងលេងដូចក្មេងអ្នកស្រុក ។

២- ន មទាយ មិនមែនដើម្បីឱ្យកើតបុរិសមានៈស្រវឹងដូចអ្នកប្រដាល់ ។

៣- ន មណ្ឌនាយ មិនមែនដើម្បីប្រដាប់តាក់តែងរាងកាយ ដូចស្ត្រីក្នុងបុរី គឺស្ត្រីអ្នកក្រុង ។

៤- ន វិភូសនាយ មិនមែនដើម្បីស្អិតស្អាងរាងកាយឱ្យមានសម្បុរផូរផង់ដូចអ្នករបាំ ។

ចាត់ជាដែនរបស់ប្រយោជន៍ ៨ យ៉ាងគឺៈ

៥- ឥមស្ស កាយស្ស ឋិតិយា ដើម្បីឱ្យតាំងនៅនៃកាយនេះ ។

៦- យាបនាយ ដើម្បីញុំាងជីវិតិន្ទ្រីយឱ្យប្រព្រឹត្តទៅ ។

៧- វិហឹសុបរតិយា ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៨- ព្រហ្មចរិយានុគ្គហាយ ដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌ ។

៩- ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ ដូច្នេះអាត្មាអញ នឹងកំចាត់បង់នៅវេទនាចាស់ គឺសេចក្ដីឃ្លាន ដែលកើតហើយផង ។

១០- នវញ្ច វេទនំ ន ឧប្បាទេស្សាមិ អាត្មាអញនឹងមិនញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ ឱ្យកើតឡើងបានផង ។

១១- យាត្រា ច មេ ភវិស្សតិ កិរិយាប្រព្រឹត្តនៃឥរិយាបថទាំង ៤ នឹងមានដល់អាត្មាអញផង ។

១២- អនវជ្ជតា ច សេចក្ដីមិនិមានទោសមានមិនច្រអូសកាយ ច្រអូសចិត្តជាដើម (នឹងមិនមានដល់អាត្មាអញផង) ។

## ចាត់ជាអានិសង្សមាន ១ គឺ:

១៣- ផាសុវិហារោ ច ការនៅសប្បាយក្នុងឥរិយាបថទាំង ៤ (នឹងមានដល់អាត្មាអញ) ផង ។

អង្គដែលត្រូវឃាត់ ៤ យ៉ាងខាងដើម សម្រាប់លះនូវឧបនិស្ស័យរបស់កិលេសគឺ:

Websites: WatKhemaraRatanaram.org or WatKhmers.org

អង្គទី ១ សម្រាប់លះនូវឧបនិស្ស័យរបស់ **មោហៈ**

អង្គទី ២ សម្រាប់លះនូវឧបនិស្ស័យរបស់ **ទោសៈ**

អង្គទី ៣ និង ៤ សម្រាប់លះនូវឧបនិស្ស័យរបស់ **រាគៈ**

អង្គក្រៅពីនេះ សម្រាប់កំណត់ដែនរបស់ប្រយោជន៍ប៉ុណ្ណោះ ។

## សេនាសនបច្ច័យ

មានកំណត់ដែនប្រយោជន៍ ៥ យ៉ាងគឺៈ

១- *សីតស្ស បដិឃាតាយ* ដើម្បីការពារនូវត្រជាក់ ។

២- *ឧណ្ហស្ស បដិឃាតាយ* ដើម្បីការពារនូវកំដៅ ។

៣- *ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ* ដើម្បីការពារនូវសម្ផស្សនៃរបោម-មូស ខ្យល់ កំដៅថ្ងៃ ពស់តូច និង ពស់ធំទាំងឡាយ ។

៤- *ឧតុបរិស្សយវិនោទនំ* ដើម្បីបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ ។

៥- *បដិសល្លានារាមត្ថំ* ដើម្បីប្រមូលចិត្តអំពីអារម្មណ៍ផ្សេងៗ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## គិលានភេសជ្ជប្បច្ច័យ

មានកំណត់ដែនរបស់ប្រយោជន៍តែ ១ យ៉ាងគឺ:

ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃា-តាយ អព្យាបជ្ឈបរមតាយ ដើម្បីការពារនូវទុក្ខវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយដរាបទៅដល់ត្រឹមប្រាសចាកសេចក្ដីទុក្ខ ។

## បរិភោគ

ការបរិភោគប្រើប្រាស់នូវបច្ច័យ ចែកតាមប្រភេទរបស់បុគ្គលអ្នកបរិភោគប្រើប្រាស់មាន ៤ យ៉ាងគឺ:

១- ថេយ្យបរិភោគ បរិភោគដោយការលួច ។

២- ឥណបរិភោគ បរិភោគដោយជាប់បំណុល ។

៣- ទាយជ្ជបរិភោគ បរិភោគនូវមត៌ក ។

៤- សាមិបរិភោគ បានបរិភោគរបស់ជនជាម្ចាស់ ។

ថេយ្យបរិភោគ បានដល់ការបរិភោគប្រើប្រាស់នូវបច្ច័យរបស់ ភិក្ខុ-សាមណេរ ទ្រុស្តសីល ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ឥណបរិភោគ** បានដល់ការបរិភោគប្រើប្រាស់នូវបច្ច័យរបស់ភិក្ខុ - សាមណេរមានសីល តែពុំបានពិចារណា ដោយបច្ចវេក្ខណៈណាមួយ ។

**ទាយជ្ជបរិភោគ** បានដល់ការបរិភោគប្រើប្រាស់នូវបច្ច័យរបស់សេក្ខបុគ្គល ៧ ពួក មានសោតាបន្នបុគ្គលជាដើម ។

**សាមិបរិភោគ** បានដល់ការបរិភោគប្រើប្រាស់នូវបច្ច័យរបស់ អសេក្ខបុគ្គល គឺព្រះខីណាស្រព ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## អតិរេកលាភ

## ចីវរប្បច្ច័យ

បព្វជិត, កាលបើមានចីវរដាច់ដាច ពុំអាចនឹងប្រើប្រាស់បានទេ, ត្រូវឱ្យស្លៀកដណ្តប់សំពត់បង្សុកូល ។ ប៉ុន្តែបើមាន អតិរេកលាភ គឺសំពត់ជាលាភពិសេសផ្សេង ក្រៅពីនោះក៏ប្រើប្រាស់ចុះ ។ សំពត់ជាអតិរេកលាភនោះ មាន ៦ យ៉ាងគឺៈ

១- ខោមំ សំពត់សំបកឈើ ។

២- កប្បាសិកំ សំពត់អម្បោះ ។

៣- កោសេយ្យំ សំពត់សូត្រ ។

៤- កម្ពលំ សំពត់រោមសត្វ ។

៥- សាណំ សំពត់ត្បាញដោយសរសៃធ្មៃជាដើម ។

៦- ភង្គំ សំពត់ត្បាញលាយចំរុះសូត្រ, អម្បោះ ។ល។

## បិណ្ឌបាតប្បច្ច័យ

បព្វជិត ចិញ្ចឹមជីវិតដោយបិណ្ឌិយាលោបនភោជន គឺចង្ហាន់ដែលបានមកដោយដើរបិណ្ឌបាត ។ ប៉ុន្តែបើមានអតិរេកលាភ គឺចង្ហាន់ជាលាភពិសេសផ្សេង ក្រៅពីនោះក៏ឱ្យឆាន់ចុះ ។ ចង្ហាន់ជាអតិរេកលាភនោះ មាន ៧ យ៉ាងគឺ ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

១- *សង្ឃភត្តំ* ភត្តប្រគេនចំពោះសង្ឃ ។

២- *ឧទ្ទេសភត្តំ* ភត្តសង្ឃសំដែងចំពោះភិក្ខុ ១ រូប ឬ ពីររូប ។

៣- *និមន្តនំ* ភត្តទាយកនិមន្តឆាន់តាមសទ្ធា ។

៤- *សលាកភត្តំ* ភត្តប្រគេនដោយចាប់ស្លាក ។

៥- *បក្ខិកំ* ភត្តប្រគេនខាងខ្នើត ឬ ខាងរនោច ។

៦- *ឧបោសថិកំ* ភត្តប្រគេនក្នុងថ្ងៃឧបោសថ ។

៧- *បាដិបទិកំ* ភត្តប្រគេនក្នុងថ្ងៃ ១ កើត ឬ ១ រោច ។

## សេនាសនបច្ច័យ

បព្វជិត ត្រូវយកម្លប់ឈើជាលំនៅ ។ ប៉ុន្តែបើមានអតិរេកលាភ គឺលំនៅជាលាភពិសេសផ្សេង ក្រៅពីនោះក៏ឱ្យនៅអាស្រ័យចុះ ។ លំនៅជាអតិរេកលាភនោះ មាន ៥ យ៉ាងគឺ:

១- *វិហារោ* កុដិធំ ឬសាលា ។

២- *អឌ្ឍយោគោ* បង្ហា ។

៣- *បាសាទោ* ប្រាសាទ ឬកុដិថែវមានជាន់ច្រើន ។

៤- *ហម្មិយំ* ប្រាសាទមានកំពូល ឬឥតកំពូល ឬក៏ថែវទាប ។

៥- *គុហា* រូងភ្នំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ភេសជ្ជប្បច្ច័យ

បព្វជិត ត្រូវឧស្សាហ៍ឆាន់ថ្នាំរម្ងាប់រោគត្រាំទឹកមូត្រ ។ ប៉ុន្តែបើមានអតិរេកលាភ គឺភេសជ្ជៈជាលាភពិសេសផ្សេង ក្រៅពីនោះក៏ឱ្យឆាន់ចុះ ។ ភេសជ្ជៈជាអតិរេកលាភនោះ មាន ៥ យ៉ាងគឺៈ

១- សប្បិ ទឹកដោះរាវ ។

២- នវនីតំ ទឹកដោះខាប់ ។

៣- តេលំ ប្រេង ។

៤- មធុ ទឹកឃ្មុំ ។

៥- ផាណិតំ ស្ករអំពៅ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# កាលិក ៤ យ៉ាង

វត្ថុដែលបរិភោគក្នុងកាល ឬប្រកបដោយកាលហៅថា កាលិក
មាន ៤ យ៉ាងគឺ:

១- យាវកាលិក

២- យាមកាលិក

៣- សត្តាហកាលិក

៤- យាវជីវិត

ក- វត្ថុទទួលប្រគេនហើយ ទុកឆាន់តាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់ អស់អំណាចហៅថា **យាវកាលិក** បានដល់ ខាទនីយៈ និងភោជនីយាហា គឺបង្អែម និង ចំអាប ត្រី សាច់ អង្ករ ជាដើម ។

ខ-វត្ថុទទួលប្រគេនហើយ ទុកឆាន់បានតែត្រឹម ១ ថ្ងៃ ១ យប់ ហៅថា **យាមកាលិក** បានដល់ទឹក អដ្ឋបាន ៨ យ៉ាងគឺ:

១- អម្ពបានំ ទឹកផ្លែស្វាយ ។

២- ជម្ពុបានំ ទឹកផ្លែព្រីង ។

៣- ចោចបានំ ទឹកផ្លែចេកមានគ្រាប់ ។

៤- មោចបានំ ទឹកផ្លែចេកឥតគ្រាប់ ។

៥- មធុបានំ ទឹកផ្លែស្រគំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៦- មុទ្ទិកបានំ ទឹកផ្លែចន្ទន៍ ។

៧- សាលុកបានំ ទឹកមើមក្រឱឈូក ។

៨- ផារុសកបានំ ទឹកផ្លែមាក់ប្រាង ។

បានដល់ទឹកអដ្ឋបាន ៨ យ៉ាងទៀតគឺៈ

១- កោសម្ពបានំ ទឹកផ្លែសង្ឃ័រ

២- កោលបានំ ទឹកផ្លែពុទ្រាតូច

៣- ពទរបានំ ទឹកផ្លែពុទ្រាធំ

៤- ឃតបានំ ទឹកដោះរាវ ឬ ទឹកដោះថ្លា

៥- តេលបានំ ទឹកធ្វើអំពីប្រេងល្ងជាដើម

៦- បយោជនំ ទឹកដោះស្រស់

៧- យាគុបានំ ទឹកបបរ

៨- រសបានំ ទឹកធ្វើពីរសរុក្ខជាតិផ្សេងៗមាន ស្លឹក និង ផ្កាជាដើម ។

គ- វត្ថុដែលទទួលប្រគេនហើយ ទុកឆាន់បានតែត្រឹម ៧ ថ្ងៃ ហៅថា សត្តាហកាលិក បានដល់ភេសជ្ជៈ ៥ យ៉ាង គឺៈ

១- សប្បិ ទឹកដោះរាវ

២- នវនីតំ ទឹកដោះខាប់

Websites: WatKhemaraRatanaram.org or WatKhmers.org

៣- តេលំ ប្រេង

៤- មធុ ទឹកឃ្មុំ

៥- ផាណិតំ ស្ករអំពៅ

ឃ- វត្ថុទទួលប្រគេនហើយ ទុកឆាន់ទាល់តែអស់ ហៅថា យាវជីវិក បានដល់ ថ្នាំកែរោគផ្សេងៗ ឬថ្នាំផ្សំពីឫសឈើ មើមឈើ ស្លឹកឈើ និងផ្លែឈើ ដូចជា:

១- ហលិទ្ទំ មើមរមៀត

២- សិង្គវេរំ មើមខ្ញី

៣- វចំ មើមលំពាន់

៤- វចត្តំ មើមប្រស់

៥- អតិវិសំ មើមអាចម៍ឆ្អឹស

៦- កដុករោហិណី មើមរំដេង

៧- ឧសីរំ ដើមស្បូវភ្លាំង

៨- ភទ្ទមុត្តកំ មើមស្មៅក្រវាញជ្រូក

**ថ្នាំផ្សំពីស្លឹកដូចជា:**

១- និម្ពបណ្ណំ ស្លឹកស្ដៅ

២- កុដជបណ្ណំ ស្លឹកស្លែងគង់

៣- បដោលបណ្ណំ ស្លឹកអម្បែងថ្ងៃ

៤- សលលិបណ្ណំ ស្លឹកម្រះព្រៅឬជីរលីងលាក់

៥- កប្បាសិបណ្ណំ ស្លឹកកប្បាសជាដើម ។

## ថ្នាំផ្សំពីផ្លែឈើ ដូចជា:

១- វិលង្គំ ផ្លែពិលង្គ

២- បិប្ផលិ ផ្លែដីប្លី

៣- មរិចំ ផ្លែម្រេច

៤- ហរីតកំ ផ្លែសម៉

៥- វិភីតកំ ផ្លែសម៉ពិភេក

៦- អាមលកំ ផ្លែកន្ទួតព្រៃ

៧- គោដផលំ ផ្លែក្រវាញ ជាដើម ។

## កាលិកលាយគ្នា

កាលិកខ្លះលាយនឹងកាលិកដទៃ មានកំណត់ឱ្យប្រើបានត្រឹមកាលរបស់កាលិកដែលមានកាលខ្លី ឧទាហរណ៍ ថ្នាំបុកផង់ជាយាវជីវិក យកទៅច្របល់លាយនឹងទឹកឃ្មុំជាសត្តាហកាលិក ថ្នាំនោះក៏មានកាលត្រឹម ៧ ថ្ងៃទៅតាមគ្នា ។ គ្រឿងទេសដូចជាក្រវ៉ាញ កាន់ភ្លូ ជាយាវជីវិក គេតាក់តែងផ្សំនឹងបាយដែលដាំដោយខ្ទិះដូង ក៏ក្លាយទៅជាយាវកាលិកតាមគ្នា។

Websites: WatKhemaraRatanaram.org or WatKhmers.org

សត្តាហកាលិក និងយាវជីវិក ដែលទទួលប្រគេនមួយយប់ហើយ លោកហាមមិនឱ្យយកទៅលាយនឹងយាវកាលិកឆាន់ទេ ឧបមាៈ យកស្ករ ដែលទទួលប្រគេនទុកមួយយប់ហើយឆាន់ជាមួយនំ ។ លោកហាមក្នុង សត្តសត្តិកក្ខន្ធកៈ ពោលក្នុងគ្រាធ្វើទុតិយសង្គាយនា ។ គម្ពីរចូឡវគ្គ លោកប្រាប់ថាត្រូវទោស ព្រោះឆាន់របស់ជា សន្និធិ លាយជាមួយទឹក អដ្ឋបានៈ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## ស្រូវ ៧ យ៉ាង:

ទ្រង់អនុញ្ញាត ទឹកផ្លែឈើគ្រប់យ៉ាង វៀរតែផ្លែស្រូវ ៧ យ៉ាង ចេញ ធ្វើទឹកអដ្ឋបាន ពុំបាន ។ ស្រូវ ៧ យ៉ាងគឺ:

១- សាលិ ស្រូវសាលី

២- វិហី ស្រូវខ្សាយ

៣- យវោ ស្រូវដំណើប

៤- គោធុមោ ស្រងែ

៥- កង្គុ ថ្ពៅ

៦- វរកោ ពោត-ស្គួយឬស្មៅកន្ទុយដំរី

៧- កុទ្រូសកោ ស្មៅគែលលក ។

## មហាផល ៩ យ៉ាង

ផ្លែឈើធំៗ ហៅថា មហាផល ៗ នេះទ្រង់ហាមមិនឱ្យធ្វើទឹកអដ្ឋបានដែរ ។ មហាផលនោះមាន ៩ យ៉ាងគឺ:

១- នាឡិកេរផលំ ផ្លែដូង

២- តាលផលំ ផ្លែត្នោត

៣- បនសផលំ ផ្លែខ្នុរ

៤- សពុជផលំ ផ្លែខ្នុរសម្ល

៥- តិបុសផលំ ផ្លែឪឡឹក

Websites: WatKhemaraRatanaram.org or WatKhmers.org

៦- បុស្សផលំ ផ្លែត្រសក់
៧- ឯឡាលុកផលំ ផ្លែត្រឡាច
៨- កុម្ភណ្ឌផលំ ផ្លែល្ពៅ
៩- អាលាពុផលំ ផ្លែឃ្លោក

## វត្ត

ទំនៀមទម្លាប់ បវេណីដែលភិក្ខុ-សាមណេរគួរប្រព្រឹត្ត ក្នុងកាលនោះៗ ក្នុងទីឋាន កិច្ច និង បុគ្គល ហៅថា វត្ត ចែកចេញជា ៣ យ៉ាងគឺ៖

១- **កិច្ចវត្ត** វត្តគឺកិច្ចដែលគួរធ្វើ
២- **ចរិយាវត្ត** វត្តគឺមារយាទគួរប្រព្រឹត្ត
៣- **វិធីវត្ត** វត្តគឺបវេណី ។

**កិច្ចវត្ត** បានដល់ករណីកិច្ចដែលបព្វជិតគប្បីធ្វើចំពោះបុគ្គល និង ទីឋាន ដូចអាគន្តុកវត្ត និងសេនាសនវត្ត ជាដើម ។

**ចរិយាវត្ត** បានដល់អាចារៈ ដែលឱ្យរក្សាដោយការសង្រួម ដូច ជាមិនចាប់ពាល់សស្ត្រាវុធ ជាដើម ។

**វិធីវត្ត** បានដល់បែបផែន ដែលឱ្យធ្វើ ដូចក្រងចីពរ បត់សំពត់ ប្រើបាត្រជាអាទិ៍ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# កិច្ចវត្តមាន ១០ យ៉ាងគឺៈ

១- ភិក្ខុ-សាមណេរ ជាសទ្ធិវិហារិក គួរយកចិត្តទុកដាក់បំរើឧបជ្ឈាយ៍របស់ខ្លួន អស់កាលដែលអាស្រ័យនៅនឹងលោក ។

២- ភិក្ខុជាឧបជ្ឈាយ៍ មានចិត្តអើពើតបសទ្ធិវិហារិកវិញ អស់កាលដែលសទ្ធិវិហារិកនោះនៅជាមួយ ។

៣- ភិក្ខុ-សាមណេរ ជាអាគន្តុកៈ ត្រូវប្រព្រឹត្តឱ្យសមគួរជាភ្ញៀវ ។

៤- ភិក្ខុ-សាមណេរ ជាម្ចាស់ទីកន្លែង កាលបើមានអាគន្តុកៈ ត្រូវធ្វើបដិសណ្ឋារៈដោយសមគួរ ។

៥- ភិក្ខុ-សាមណេរ មុននឹងចេញទៅទីដទៃ ត្រូវរៀបចំទុកដាក់គ្រឿងសម្ភារៈឱ្យស្អាតបាត ។

៦- មុនចូលបិណ្ឌបាតក្នុងលង្វែកភូមិ គួរប្រព្រឹត្តខ្លួនឱ្យត្រឹមត្រូវតាមទំនៀម ។

៧- ឆាន់អាហារ គួរប្រព្រឹត្តឱ្យត្រឹមត្រូវ ។

៨- ភិក្ខុ-សាមណេរមានម្លប់ឈើជាអាសនៈ តែបើក្នុងវស្សា ត្រូវរកសេនាសនៈ ដែលជាទីគត់ភ្លៀង ដែលមនុស្សធ្វើ ឬធ្វើដោយខ្លួនឯង ។

៩- ភិក្ខុ-សាមណេរ គួររក្សាឱ្យស្អាតក្នុងវច្ចកុដិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

១០- គួរជួយព្យាបាលភិក្ខុ-សាមណេរ ដែលមានអាពាធ តាមកាលគួរ ។

## ចរិយាវត្ត

ចរិយាវត្តនេះ ពោលដោយសង្ខេបមាន ១០ យ៉ាងគឺ:

១- មិនឱ្យជាន់ផ្ចត់សំពត់ស ដែលគេលាតក្នុងទីនិមន្ត ។

២- មិនទាន់បានពិចារណាជាមុនកុំអាលអង្គុយលើអាសនៈ ។

៣- មិនត្រូវអង្គុយលើអាសនៈវែងជាមួយនឹងស្ត្រី ឬ មនុស្សខ្ទើយ តែបើអង្គុយជាមួយមនុស្សមានអាសនៈមិនស្មើគ្នាបាន ។

៤- ភិក្ខុ-សាមណេរកំពុងឆាន់មិនត្រូវក្រោកចោល ។

៥- មុនសឹងសំរាកក្នុងវេលាថ្ងៃ ត្រូវបិតទ្វារ ។

៦- មិនត្រូវបន្ទោបង់ឧច្ចារៈ បស្សាវៈ ចោលសម្រាម ឬ របស់ជាសំណល់ទៅក្រៅជញ្ជាំង ឬ ក្រៅកំពែង ។

៧- មិនត្រូវឡើងដើមឈើ វៀរលែងតែមានកិច្ច ដូចជាវង្វេងផ្លូវ ។

៨- មិនត្រូវទៅមើលរាំ ស្តាប់ច្រៀង ឬប្រគំ ។

៩- មិនត្រូវសូត្រធម៌ ដោយសម្លេងច្រៀងដ៏វែង ។

១០- មិនត្រូវចាប់ពាល់វត្ថុជាអនាមាសៈ ៦ យ៉ាង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## វត្ថុអនាមាសៈ

វត្ថុដែលមិនគួរចាប់ពាល់ ហៅថា វត្ថុអនាមាសៈ ចែកចេញជា ៦ យ៉ាងគឺៈ

១- ស្រ្តីព្រមទាំងគ្រឿងតែងខ្លួនរបស់ស្ត្រី និងរូបរាង ដែលធ្វើមានទ្រង់ទ្រាយជាស្រ្តី ។

២- មាស-ប្រាក់ និងរតនៈ ។

៣- សស្ត្រាវុធផ្សេងៗ ជាគ្រឿងប្រទូស្តនៃរាងកាយ ឯគ្រឿងធ្វើការងារ ដូចជាពូថៅជាដើម មិនរាប់បញ្ចូលក្នុងពួកនេះទេ ។

៤- គ្រឿងដាក់ចាប់សត្វលើគោក ក្នុងទឹក ។

៥- គ្រឿងប្រគំគ្រប់បែប ។

៦- គ្រាប់ស្រូវនិងផ្លែឈើ ដែលជាប់នៅនឹងដើម ។

## វិធីវត្ត

បែបផែនទំនៀមទម្លាប់ ដែលភិក្ខុ-សាមណេរ គួរប្រព្រឹត្ត ប្រតិបត្តិតាម ហៅថា វិធីវត្ត ។ វិធីវត្តនេះ លោកពោលជាបែបផែនមិនស្ថិតស្ថេរ តែងផ្លាស់ប្តូរ ទៅតាម កាលៈទេសៈ ។ វិធីបត់ចីពរ គឺមិនឱ្យបត់កាច់ចំកណ្តាល របៀបទុកចីពរលើខ្សែស្បៀង, វិធីទុកបាត្រ វិធីជូតទ្រនាប់ជើងដោយសំពត់ស្ងួតមុន ហើយសឹមយកសំពត់ទទឹក ជូតជាខាងក្រោយ ជាដើម ទាំងអស់នេះ ហៅថា វិធីវត្ត ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# អធិដ្ឋាន

ព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាត ឱ្យសាមណេរ ប្រើប្រាស់បរិក្ខារ ដូចជាភិក្ខុដែរ វៀរលែងតែសង្ឃាដី និងនិសីទនៈ ។ ដូច្នេះ បរិក្ខារ ដែលត្រូវប្រើប្រាស់នេះ ត្រូវអធិដ្ឋាន ប្រែថា តាំងទុក ។ មុនអធិដ្ឋាន សាមណេរគប្បីយកសំពត់នោះ ទៅបោកជ្រលក់ឱ្យបានស្អាតរួចហើយ រៀបចំបត់ឱ្យរៀបរយ ។ បន្ទាប់មកត្រូវយកដៃខ្មៅ ឬវត្ថុអ្វីដែលអាចគូសចំណាំបាន ធ្វើពិន្ទុទៅលើជាយសំពត់ ដែលបំរុងនឹងអធិដ្ឋាន មានទំហំកុំឱ្យលើសពីភ្នែកមាន់ ដោយសូត្របាលីថា:

**ឥមំ ពិន្ទុកប្បំ ករោមិ ។**

**ទុតិយម្បិ ឥមំ ពិន្ទុកប្បំ ករោមិ ។**

**តតិយម្បិ ឥមំ ពិន្ទុកប្បំ ករោមិ ។**

ប្រែថា: អាត្មាអញធ្វើនូវគ្រឿងសំគាល់ដោយចំណុចនេះ ។

....អស់វារៈ ពីរដងផង ។

....អស់វារៈ បីដងផង ។

រួចហើយ ចាប់សំពត់នោះលើកឡើង សូត្រអធិដ្ឋានតាមឈ្មោះ ។ បើអធិដ្ឋាន ចីវរជាឧត្តរាសង្គៈ (ចីពរ) សូត្រថា **ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ** ប្រែថា អាត្មាអញតាំងទុកនូវសំពត់ ឧត្តរាសង្គៈ នេះ ឬថា "អាត្មាអញអធិដ្ឋាននូវសំពត់នេះជា ឧត្តរាសង្គៈ គឺចីវរ " ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បើអធិដ្ឋានបរិក្ខារដទៃទៀត គប្បីលើកយកបទ **ឧត្តរាសង្គំ** ចេញ ហើយបញ្ចូលទៅតាមឈ្មោះដូច្នេះ ។

| | |
|---|---|
| **អន្តរវាសកំ** | នូវស្បង់ |
| **វស្សិកសាដិកំ** | នូវសំពត់ងូតទឹកភ្លៀង |
| **ឧទកសាដិកំ** | នូវសំពត់ងូតទឹក |
| **មុខបុញ្ឆនចោលំ** | នូវកន្សែងជូតមុខ |
| **កណ្ឌុប្បដិច្ឆាទី** | នូវសំពត់រុំដំបៅ |

កាលនឹងអធិដ្ឋាន បើបរិក្ខារដែលអធិដ្ឋានមុននៅ ហើយត្រូវការផ្លាស់ជាថ្មី គប្បីដកអធិដ្ឋានចេញសិន។ ការដកនេះហៅថា បច្ចុទ្ធរណៈ។ លើកសំដែង ឧត្តរាសង្គៈជាតួយ៉ាងថា **ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ** ប្រែថា អាត្មាអញដក ឧត្តរាសង្គៈនេះ ។ បរិក្ខារដទៃទៀតមានទំនង់ដូចគ្នា ប្លែកតែឈ្មោះ ។

ចំណាំៈ តាមទំនៀម មុនអធិដ្ឋាន គប្បីធ្វើនមស្សការសូត្រ **នមោ** ៣ ចប់ ។

## អធិដ្ឋានមាន ២ យ៉ាងគឺៈ

អធិដ្ឋានដោយកាយ ១ ។

អធិដ្ឋានដោយវាចា ១ ។

អធិដ្ឋានដោយកាយនោះ គឺយកដៃចាប់ឬអង្អែលបរិក្ខារដែលអធិដ្ឋាន

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះធ្វើសេចក្ដីចង់ចិត្តតាមពាក្យអធិដ្ឋានខាងដើម ។

អធិដ្ឋានដោយវាចា គឺបញ្ចេញសំឡេងអធិដ្ឋាន មិនចាប់ពាល់របស់ដោយកាយក៏បាន ចែញចេញទៅជា ២ គឺៈ

អធិដ្ឋាន ក្នុងហត្ថបាស ១

អធិដ្ឋាន ក្រៅហត្ថបាស ១

បរិក្ខារនៅខាងក្នុង ២ ហត្ថ ១ ចំអាម ឬ ១ ហត្ថ គប្បីប្រើអធិដ្ឋានក្នុងហត្ថបាសបញ្ចេញវាចាតាមបែបនោះ ។ បើរបស់នៅឃ្លាតឆ្ងាយគប្បីប្រើអធិដ្ឋានក្រៅហត្ថបាស បញ្ចេញវាចាថា **ឯតំ ឧត្តរាសង្គំ អធិ-ដ្ឋាមិ** ប្រែថា អាត្មាអញអធិដ្ឋាននូវសំពត់ទុំះឱ្យជាឧត្តរាសង្គៈ ។ បរិក្ខារក្រៅពីនេះ មានទំនងដូចគ្នា ។

## ដាច់អធិដ្ឋាន

បរិក្ខារដែលសាមណេរអធិដ្ឋាន ដោយឈ្មោះដូចពោលមកហើយនឹងដាច់អធិដ្ឋានទៅវិញ ដោយហេតុ ៩ យ៉ាងគឺៈ

១- ឱ្យដល់អ្នកដទៃ

២- ចោរលួចឬដណ្ដើមយកទៅ

៣- មិត្រកាន់យកដោយសេចក្ដីស្និទ្ធស្នាល

៤- ម្ចាស់បិក្ខារ ប្រែភាវៈជាមនុស្សថោកទាប ដូចជាត្រូវនាសនង្គៈ ឬចូលលទ្ធិដទៃ ។

៥- លាចាកសិក្ខា

៦- ធ្វើកាលកិរិយា

៧- ប្រែភេទប្រុសជាស្ត្រីក្នុងរឿងវិនីតវត្ថុនៃបារាជិក

៨- ដកចេញពីអធិដ្ឋាន

៩- ដាច់ធ្លុះជាប្រហោងប៉ុនខ្នងក្រចកកូនដៃ មិនមានសរសៃអម្បោះក្នុងចន្លោះ រាប់អំពីជាយសំពត់ចូលទៅខាងបណ្ដោយ ១ ចំអាម ខាងទទឹង ៤ ធ្នាប់ ។

# បាលីយកវត្ត

កិច្ចយកវត្ត ព្រះឧបជ្ឈាយ៍ ឬអាចារ្យនេះ ជាទំនៀមបព្វជិតក្នុងព្រះពុទ្ធសាសនា ហើយខានពុំបានផង ។ ឯរបៀបយកវត្តនោះ មានដូចតទៅ ៖

សទ្ធិវិហារិក ឬ អន្តេវាសិក គប្បីកាន់យកគ្រឿងសក្ការៈ មានទៀន ធូប បារី ជាដើម ចូលទៅរកព្រះឧបជ្ឈាយ៍ ឬអាចារ្យ ប្រគេនគ្រឿងសក្ការៈនោះទៅលោក ហើយក្រោកឈរឡើងសូត្រថា:

**ឱកាស វន្ទាមិ ភន្តេ សព្វំ អបរាធំ ខមថ មេ ភន្តេ មយា កតំ បុញ្ញំ សាមិនា អនុមោទិតព្វំ សាមិនា កតំ បុញ្ញំ មយ្ហំ ទាតព្វំ សាធុ សាធុ អនុមោទាមិ ។**

ប្រែមានក្នុងបព្វជ្ជាវិធីខាងដើម ។ រួចហើយ អង្គុយច្រហោងប្រណម្យអញ្ជលី សូត្រថា:

**សព្វំ អបរាធំ ខមថ មេ ភន្តេ ។**

ក្រាបចុះ សូត្រថា:

**ឱកាស ទ្វារត្តយេន កតំ សព្វំ អបរាធំ ខមថ មេ ភន្តេ ។**

ព្រះឧបជ្ឈាយ៍ ឬអាចារ្យ លោកឱ្យពរ សព្ទសាធុការឱ្យបានចំរុងចំរើនព្រះពុទ្ធសាសនា ឬ លោកសូត្រពុទ្ធពរ ៤ ប្រការជាដើម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

គប្បីទទួលតបថា៖

**ឱកាស ខមាមិ ភន្តេ ។**

ក្រោកឈរឡើងប្រណម្យអញ្ជលី សូត្រថា៖

**វន្ទាមិ ភន្តេ ។ល ។ សាធុ សាធុ អនុមោទាមិ ។**

ចប់ពិធីយកវត្តតែប៉ុណ្ណេះ ៕

Websites: WatKhemaraRatanaram.org or WatKhmers.org

## ការចូលវស្សា

តាមទំនៀមព្រះពុទ្ធសាសនា តែដល់វស្សានរដូវហើយ គឺចាប់តាំងពីថ្ងៃ ១ រោច ខែអាសាធ រហូតទល់នឹងថ្ងៃ ១៥ កើត ខែកត្តិក រយៈកាល ៤ ខែនេះ ភិក្ខុ-សាមណេរ ពុំត្រូវត្រាច់ចររហេតរហូតទេ ត្រូវរកទីលំនៅឈប់សំរាកមួយកន្លែង អស់ថិរវេលា ៣ ខែ ដែលលោកហៅថា ចាំវស្សា ។

## ការចាំវស្សាមាន ២ លើកគឺ:

លើកដំបូង, ភិក្ខុ-សាមណេរត្រូវចូលវស្សាពីថ្ងៃ ១ រោច ខែអាសាធ ឬទុតិយាសាធ រហូតទល់នឹងថ្ងៃ ១៥ កើត ខែអស្សុជ ។ ចូលរបៀបនេះ ហៅថា បុរិមិកាវស្សា ។

លើកក្រោយ, ចូលវស្សាពីថ្ងៃ ១ រោច ខែស្រាពណ៍ រហូតទៅទល់ថ្ងៃ ១៥ កើត ខែកត្តិក ។ ចូលរបៀបនេះហៅថា *បច្ឆិមិកាវស្សា* ។

## បាលីចូលវស្សា

នៅថ្ងៃចូលវស្សា សាមណេរទាំងឡាយ មិនត្រូវដើរចេញពីអាវាសឡើយ គប្បីជួយរៀបចំអាវាស ទីបរិវេណ ព្រះវិហារ ដំកល់ទឹកឆាន់ ទឹកប្រើប្រាស់ប្រគេនភិក្ខុសង្ឃ បន្ទាប់ពីភិក្ខុសង្ឃចូលវស្សារួចហើយ សាម-ណេរ គប្បីប្រជុំគ្នាក្នុងព្រះវិហារ អធិដ្ឋានចូលវស្សាព្រមគ្នាថា:

Websites: WatKhemaraRatanaram.org or WatKhmers.org

ឥមស្មឹ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេម

ប្រែថា: យើងទាំងឡាយ នៅចាំវស្សាអស់ខែ ៣ នេះ ក្នុងអាវាសនេះ ។ ថាតែត្រឹមបាលី ៣ ដង ប្រែមិនបាច់ថាទេ ។

## សត្តាហករណីយ:

សាមណេរចូលវស្សាក្នុងទីណាហើយ ត្រូវនៅរក្សារាត្រីក្នុងទីនោះរហូតកំណត់ ៣ ខែ បើមានធុរៈអាចចេញដើរបាន តែត្រូវវិលមកវិញឱ្យបានមុនថ្ងៃរះក្នុងថ្ងៃទី ៧ ។

បើមានធុរៈចំពោះ មាតា-បិតា និង ភិក្ខុ-សាមណេរ ដែលខ្លួនបានដឹងហើយ សាមណេរអាចលើកសត្តាហៈទៅបាន ដោយមិនបាច់មានការនិមន្តទ៏ទេ, តែបើឧបាសក ឧបាសិកា បង ប្អូន ញាតិ មានធុរៈលុះណាតែមានការនិមន្តទ៏ ទើបទៅដោយសត្តាហៈបាន ។ មុននឹងចេញពីអាវាស ត្រូវអធិដ្ឋានថា:

សចេ មេ អន្តរាយោ នត្ថិ, សត្តាហព្ភន្តរេយេវ បុន និវត្តិស្សាមិ ។

ទុតិយម្បិ សចេ មេ ។ល។ និវត្តិស្សាមិ ។

តតិយម្បិ សចេ មេ ។ល។ និវត្តិស្សាមិ ។

ប្រែថា: បើមិនមានអន្តរាយដល់អាត្មាអញទេ, អាត្មាអញនឹងត្រឡប់មកវិញ ក្នុងចន្លោះសត្តាហៈពុំខាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

. . . . ជាគម្រប់ពីរដងផង ។

. . . . ជាគម្រប់បីដងផង ។

## ការលាសិក្ខា

ភិក្ខុ-សាមណេរ អ្នកនឿយណាយក្នុងការប្រព្រឹត្តិព្រហ្មចរិយធម៌ មានប្រាថ្នានឹងត្រឡប់មកកាន់ភេទជាគ្រហស្ថ រមែងធ្វើបានដោយការលាសិក្ខា ។

ឯការលាសិក្ខានេះ ក្នុងគម្ពីរកង្ខាវិតរណីបឋមបារាជិក សំដែងថាត្រូវប្រកបអង្គ ៦ យ៉ាងគឺៈ

ចិត្ត ១, ខេត្ត ១, កាល ១, បយោគ ១, បុគ្គល ១, វិជាននៈ ១ ។

### ១-ចិត្ត

អ្នកលាសិក្ខា ត្រូវធ្វើដោយតាំងចិត្ត ដើម្បីលាសិក្ខាពិតៗ បើគ្រាន់តែថាលេង ឬទន្ទេញពាក្យលា ពោលដោយការរៀន ឬក៏សំដែងវិន័យកថាមិនរាប់ថាលាទេ ។

### ២-ខេត្ត

សំដៅយក ខេត្តបទ ២២ យ៉ាងគឺៈ ខេត្តបទសម្រាប់ពោលលា ១៤ យ៉ាង និងខេត្តបទ សម្រាប់ទ្រទ្រង់ភេទជាថ្មី ៨ យ៉ាង។ ខេត្តបទសម្រាប់ពោលលា ១៤ យ៉ាងនេះគឺៈ

Websites: WatKhemaraRatanaram.org or WatKhmers.org

-ពុទ្ធំ បច្ចក្ខាមិ ខ្ញុំសូមលាព្រះពុទ្ធ ១

-ធម្មំ បច្ចក្ខាមិ ខ្ញុំសូមលាព្រះធម៌ ១

-សង្ឃំ បច្ចក្ខាមិ ខ្ញុំសូមលាព្រះសង្ឃ ១

-សិក្ខំ បច្ចក្ខាមិ ខ្ញុំសូមលាសិក្ខា ១

-វិនយំ បច្ចក្ខាមិ ខ្ញុំសូមលាវិន័យ ១

-បាតិមោក្ខំ បច្ចក្ខាមិ ខ្ញុំសូមលាបាតិមោក្ខ ១

-ឧទ្ទេសំ បច្ចក្ខាមិ ខ្ញុំសូមលាឧទ្ទេស ១

-ឧបជ្ឈាយំ បច្ចក្ខាមិ ខ្ញុំសូមលាព្រះឧបជ្ឈាយ៍

-អាចរិយំ បច្ចក្ខាមិ ខ្ញុំសូមលាអាចារ្យ ១

-សទ្ធិវិហារិកំ បច្ចក្ខាមិ ខ្ញុំសូមលាសទ្ធិវិហារិក ១

-អន្តេវាសិកំ បច្ចក្ខាមិ ខ្ញុំសូមលាអន្តេវាសិក ១

-សមានុបជ្ឈាយកំ បច្ចក្ខាមិ ខ្ញុំសូមលាសមានុបជ្ឈាយ៍ ១

-សមានាចរិយកំ បច្ចក្ខាមិ ខ្ញុំសូមលាសមានចរិយក៍ ១

-សព្រហ្មចារី បច្ចក្ខាមិ ខ្ញុំសូមលាសព្រហ្មចារី ១

ខេត្តបទ សម្រាប់ទ្រទ្រង់ភេទជាថ្មី ៨ យ៉ាងនោះគឺៈ

-គិហីតិ មំ ធារេថ សូមលោកម្ចាស់ទាំងឡាយ ចាំទុកនូវខ្ញុំថា ជាគ្រហស្ថ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

-ឧបាសកោតិ មំ ធារេថ សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថា ជាឧបាសក ១ ។

-អារាមិកោតិ មំ ធារេថ សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជាអារាមិកជន ១ ។

-សាមណេរោតិ មំ ធារេថ សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថាជាសាមណេរ ១ ។

-តិត្ថិយោតិ មំ ធារេថ សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថា ជាតិរ្ថិយ៍ ១ ។

-តិត្ថិយសាវកោតិ មំ ធារេថ សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថា ជាសាវកតិរ្ថិយ៍ ។

-អស្សមណោតិ មំ ធារេថ សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថា ជាបុគ្គលមិនមែនជាសមណៈ ១ ។

-អសក្យបុត្តិយោតិ មំ ធារេថ សូមលោកម្ចាស់ទាំងឡាយចាំទុកនូវខ្ញុំថា ជាបុគ្គលមិនមែនជាសក្យបុត្តិយ ១ ។

រួមត្រូវជាខេត្តបទ ២២ ប្រការ ។

ក្នុងខេត្តបទ ២២ ប្រការនេះ អ្នកលាសិក្ខា គប្បីពោលលាតែខេត្តបទណាមួយដែលខ្លួនចង់លា ហើយទ្រទ្រង់ខេត្តបទណាមួយ ដែលខ្លួនស្រឡាញ់ ។ ឧបមាថាៈ បើលាព្រះពុទ្ធ អ្នកនោះឯង មានប្រាថ្នាចូលសាសនាដទៃ ត្រូវលាថាៈ

Websites: WatKhemaraRatanaram.org or WatKhmers.org

## ពុទ្ធំ បច្ចក្ខាមិ, តិត្ថិយោតិ មំ ធារេថ

ខ្ញុំសូមលាព្រះពុទ្ធ, សូមលោកម្ចាស់ទាំងឡាយ ចាំទុកខ្ញុំថាជាតិរ្ថិយ៍ ។ ពោលលាបែបនេះ ឈ្មោះថាដាច់ចាកភេទជាបព្វជិត ហើយថែមទាំងដាច់ចាកភេទជាពុទ្ធបរិស័ទទៀត ។

លោកអាចារ្យជាច្រើន ពោលថា: ប្រទេសយើងជាអ្នកកាន់ព្រះពុទ្ធសាសនា ពុំគួរពោលលា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃទេ បើលោកអ្នកលានោះ ជាសាមណេរ លាត្រឹមតែសិក្ខា, វិន័យ, ឧទ្ទេស រៀរលែងតែបាតិមោក្ខ ព្រោះសាមណេរគ្មាន ហើយបើទ្រទ្រង់ភេទជាគ្រហស្ថ ត្រូវសមាទានសីល ប៉ុន្តែបើនៅថ្វាយខ្លួនជាឧបាសក គឺពោលយកភេទជាឧបាសកវិញតែម្តង ពុំបាច់សមាទានសីល ថែមទៀតក៏បាន ។

### ៣-កាល

អ្នកលាសិក្ខា ត្រូវពោលឱ្យច្បាស់ កុំឱ្យច្រឡំកាល ដូចជាពោលថា ខ្ញុំនឹងលា (**បច្ចក្ខិស្សំ**) ខ្ញុំព្រះករុណានឹងជាគ្រហស្ថ (**គិហីភវិស្សំ**) ។ ល ។ មិនឈ្មោះថាលាសិក្ខាឡើយ ត្រូវលាជាសមានកាលថា **សិក្ខំ បច្ចក្ខាមិ** ខ្ញុំលាសិក្ខា **គិហីតិ មំ ធារេថ** សូមព្រះករុណាទាំងឡាយចាំទុកនូវខ្ញុំថា ជាគ្រហស្ថ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## ៤-បយោគ

បយោគចែកជា ២ យ៉ាងគឺៈ កាយប្បយោគ ១, វចីបយោគ ១

**កាយប្បយោគ** គឺអ្នកលា គ្រាន់តែធ្វើកាយវិការ ឬ ផ្លាស់សំពត់កាសាយៈចេញ ស្លៀកដណ្តប់ដូចគ្រហស្ថ មិនរាប់ថាលាទេ លុះណាតែបញ្ចេញវាចាប្តេជ្ញាខ្លួនឯង ជា **វចីបយោគ** ទើបឈ្មោះថាលា ។

## ៥-បុគ្គល

បុគ្គលអ្នកលាសិក្ខា មិនមែនជាមនុស្សឆ្កួត មិនក្រឡកចិត្ត មិនមានវេទនាគ្របសង្កត់ ទាំងបុគ្គលដទៃជាសាក្សីនោះ មិនមែនជាសត្វ គឺជាមនុស្សដឹងខុសត្រូវ ហើយនៅចំពោះមុខគ្នាផង ។

## ៦-វិជាននៈ ការឱ្យដឹងច្បាស់

អ្នកលាសិក្ខា គប្បីប្រាប់អ្នកដទៃឱ្យដឹងច្បាស់ អំពីការអផ្សុកចង់សឹក នឹងប្រាប់ភេទថ្មីដែលត្រូវផ្លាស់ ។

បើប្រកបដោយអង្គទាំង ៦ នោះហើយ ឈ្មោះថាការលាសិក្ខាចប់ត្រឹមនេះ អ្នកលាសិក្ខាគប្បីផ្លាស់ភេទជាឃរាវាសចុះ ។

បាលីគាថាសម្រាប់ទន្ទេញឱ្យងាយចាំៈ

**ចិត្តំ ខេត្តញ្ច កាលោ ច**

**បយោគោ បុគ្គលោ តថា**

Websites: WatKhemaraRatanaram.org or WatKhmers.org

## វិជាននត្ថិ សិក្ខាយ
## បច្ចក្ខានំ ជឡង្គិកំ

ការលាសិក្ខា ត្រូវប្រកបដោយអង្គ ៦ យ៉ាងគឺ:

ចិត្ត ១, ខេត្ត ១, កាល ១,

បយោគ ១, បុគ្គល ១, វិជានន: ១ ។

តាមដែលធ្លាប់ដឹងតៗមកថា: ការលាសិក្ខាបទនេះ មានបាលីសម្រាប់សូត្រថា:

## ហរាយមានោ អដ្ដិយមានោ
## ជិគុច្ឆមានោ គិហីតិ មំ ធារេថ ។

ប្រែថា: ខ្ញុំព្រះករុណា នឿយណាយ ធុញទ្រាន់ខ្ពើមឆ្អើម (នឹងពុទ្ធសាសនាណាស់) សូមលោកម្ចាស់ចាំទុក នូវខ្ញុំព្រះករុណាថា ជាគ្រហស្ថចុះ ។

កាលពោលយ៉ាងនេះ ពុំគួរទេ ព្រោះខ្លួននៅកាន់ពុទ្ធសាសនា ហើយប្រកាសថា ខ្លួនខ្ពើមឆ្អើម ធុញទ្រាន់ ពុទ្ធសាសនា ។ ដូច្នេះ គួរសិក្ខាកាមកុលបុត្រ សិក្សាតាមបាលីមានក្នុងគម្ពីរ កង្ខាវិតរណី ដូចពោលខាងដើមរួចមកហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## ការផ្សាយមេត្តាគ្រប់ទិស

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបូព៌ា សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសអាគ្នេយ៍ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសទក្សិណ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសនិរតី សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបស្ចិម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសពាយ័ព្យ

Websites: WatKhemaraRatanaram.org or WatKhmers.org

សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឧត្តរ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឦសាន សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងលើ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងក្រោម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ សត្តា អវេរា ហោន្តុ** សត្វទាំងឡាយទាំងពួង សូមកុំឱ្យមានពៀរនឹងគ្នា ។

**សុខិតា ហោន្តុ** សូមឱ្យមានតែសេចក្ដីសុខ ។

**និទ្ទុក្ខា ហោន្តុ** សូមឱ្យប្រាសចាកទុក្ខ ។

**អព្យាបជ្ឈា ហោន្តុ** សូមកុំឱ្យមានព្យាបាទនឹងគ្នា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អនីឃា ហោន្តុ សូមកុំឱ្យមានសេចក្តីចង្អៀតចង្អល់ចិត្ត ។

ទីឃាយុកា ហោន្តុ សូមឱ្យមានអាយុវែង ។

អរោគា ហោន្តុ សូមកុំឱ្យមានរោគ ។

សម្បត្តីហិ សមិជ្ឈន្តុ សូមឱ្យសម្រេចដោយសម្បត្តិទាំងឡាយ ។

សុខី អត្តានំ បរិហរន្តុ សូមរក្សានូវខ្លួនឱ្យនៅជាសុខតទៅ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា
ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា
ហោន្តុ សព្វេបិ ទាណិនោ ។

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ ។

Websites: WatKhemaraRatanaram.org or WatKhmers.org




Websites: WatKhemaraRatanaram.org or WatKhmers.org